សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royal de Droit et des Sciences Économiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អំណាចមេធា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣   ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ:   កញ្ញា **តួង ច័ន្ទម៉ូនីកា**

កញ្ញា **ប៉ាន់ ហ្សូរីណា**

ណែនាំដោយ

លោក **ហ៊ីង គីមឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **តួច ច័ន្ទម៉ូនីកា** និង **ប៉ាន់ ហួរីណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៩-២០២៣។

**សូមលំឱនកាយ សម្តែងនូវការគោរពដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ជូនចំពោះ៖**

| | |
|---|---|
| លោកឪពុក **តួច ណារុធ** | លោកឪពុក **ជិម ហួរ** |
| អ្នកម្តាយ **ប៉ាង រតនា** | អ្នកម្តាយ **សុខ សុឌ្ធារី** |

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតទៅដល់លោកឪពុក អ្នកម្តាយដែលបានផ្តល់កំណើតអោយកូន និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្តីប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន។ លោកទាំងទ្វេរបានពុះពារគ្រប់ឧបសគ្គ មិនថាកម្លាំងកាយ កម្លាំងចិត្ត ផ្នែកស្មារតី ព្រមទាំងផ្នែកសម្ភារៈ ក្នុងគោលបំណងតែមួយគត់គឺចង់ឃើញកូនៗទទួលបានការអប់រំដែលល្អ។ លោកទាំងពីរជាគ្រូបាអាចារ្យ ជាអ្នកលើកទឹកចិត្តកូនគ្រប់ពេលវេលា លោកបានផ្តល់ឱកាសឲ្យយើងខ្ញុំទាំងពីរនាក់សិក្សារៀនសូត្រតាំងពីថ្នាក់កុមារដ្ឋាន រហូតដល់ថ្នាក់ឧត្តមសិក្សាដើម្បីតម្រង់ទិសឲ្យកូនៗបានក្លាយជាបុគ្គលមានតម្លៃទាំងចំពោះខ្លួនឯង គ្រួសារ និងសង្គមជាតិ។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធិបុរស** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឱ្យយើងខ្ញុំទាំងពីរទទួលបាននូវឱកាសក្នុងការចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ **លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងអំឡុងពេល៤ឆ្នាំកន្លងមកនេះយើងខ្ញុំបានទទួលនូវការអប់រំណែនាំ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្ទេរនូវចំណេះដឹងដល់ពួកយើងខ្ញុំ និងសិស្សដទៃទៀតតាំងពីថ្នាក់មូលដ្ឋានរហូតដល់បញ្ចប់បរិញ្ញាបត្រពិតជាពុំអាចកាត់ថ្លៃបាន។

ជាពិសេស យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រោលជ្រៅជូនចំពោះលោកគ្រូ សាស្ត្រាចារ្យ **ហ៊ីង គឹមឡេង** ដែលបានដឹកនាំក្នុងការសេសេរសារណាមួយនេះ ព្រមទាំងជួយណែនាំ ចង្អុលបង្ហាញផ្តល់មតិយោបល់ដំបូន្មានល្អៗ ទាំងផ្នែកស្មារតី និងឯកសារ ព្រមទាំងជួយត្រួតពិនិត្យកែតម្រូវចំណុចខ្វះខាតជាពិសេសគឺពេលវេលាដ៏មានតម្លៃរបស់លោកនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូតដល់សារណាមួយនេះបានបញ្ចប់ប្រកបដោយជោគជ័យ។

ជាទីចុងបញ្ចប់ យើងខ្ញុំ សូមលើកហត្ថាប្រណម បួងសួងដល់បារមីនៃវត្ថុសក្តិសិទ្ធិ ទេព្តា ក្នុងលោក សូមប្រសិទ្ធិពរជ័យសិរីសួស្តីជូនចំពោះ **អ្នកមានគុណទាំងពីរដែលជាលោកឪពុក និងអ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកពូ អ្នកមីង បងប្អូន និងមិត្តភក្តិទាំងអស់** ជាពិសេសលោកគ្រូ **ហ៊ីង គឹមឡេង** សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ ជោគជ័យគ្រប់ភារកិច្ច និងព្រមទាំងជួបពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល៤(បួន) ឆ្នាំមកនេះ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចយើងខ្ញុំទាំងពីរអ្នកពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានទទួលចំណេះដឹងល្អៗ និងការអប់រំផ្សេងៗទៀតពីលោកគ្រូ អ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀនយើងខ្ញុំទាំងពីរនាក់ដោយគ្មានការនឿយហត់។ យើងខ្ញុំទាំងពីរនាក់ពិតជាថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យទាំងអស់ និងសាកលវិទ្យាល័យដោយផ្តល់ឱកាសឱ្យយើងខ្ញុំក្នុងការស្រាវជ្រាវចងក្រងសារណាដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅក្រោមប្រធានបទ **អំណាចមេបា** ដើម្បីធ្វើជាសារណាសម្រាប់ឆ្នាំនេះ។

សៀវភៅសារណានេះដែរ គឺត្រូវបានខិតខំស្រាវជ្រាវដោយយកចិត្តទុកដាក់បំផុតតាមរយៈការដកស្រង់យកនូវខ្លឹមសារដែលមានសារៈប្រយោជន៍យ៉ាងចាំបាច់បំផុតដើម្បីយកមកចងក្រងជាសៀវភៅនេះឡើង។ ចំពោះការលើកយកប្រធានបទនេះមកស្រាវជ្រាវបកស្រាយក្នុងគោលបំណងពង្រីកចំណេះដឹងបន្ថែមអំពីអំណាចមេបា ព្រោះឪពុកម្តាយជាអ្នកមានសិទ្ធិអំណាចមេបាលើកូន នៅពេលដែលមានការលែងលះអំណាចមេបានឹងមានរូបភាពបែបណា ក្នុងករណីគ្មានចំណងអាពាហ៍ពិពាហ៍ នីតិវិធីច្បាប់ធ្វើការកំណត់បែបណា ហើយបន្ទាប់ពីមានការកំណត់អំពីអ្នកមានអំណាចមេបាហើយថាតើអ្នកដែលមានអំណាចមេបា និងអ្នកដែលគ្មានសិទ្ធិអំណាចមេបាត្រូវមានសិទ្ធិ និងករណីកិច្ចអ្វីខ្លះចំពោះកូន។ ម្យ៉ាងទៀតសារណាមួយនេះក៏បានតាក់តែងឡើងក្នុងគោលបំណងដើម្បីចែករំលែកចំណេះដឹង ក៏ដូចជាធ្វើជាឯកសារពិគ្រោះដល់សិស្សប្អូនផងដែរក្នុងការស្វែងយល់ និងស្រាវជ្រាវបន្ថែមអំពីប្រធានបទនេះអោយកាន់តែស៊ីជម្រៅ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមខន្តីអភ័យទោសទុកជាមុនពីសំណាក់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់នៅរាល់កំហុសខុសឆ្គង ដែលកើតមានឡើងដោយអចេតនានូវរាល់ចំណុចខ្វះខាតទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធដែលមិនត្រឹមត្រូវដោយអចេតនា ព្រមទាំងទទួលយករាល់មតិរិះគន់ក្នុងន័យស្ថាបនាផងដែរ ហើយយើងខ្ញុំទាំងពីរនាក់សូមជូនពរទៅដល់មិត្តអ្នកអានទាំងអស់អោយជួបតែពុទ្ធពរទាំង ៤(បួន) ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ...... ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ...... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ...... ១

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ...... ១

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ...... ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ...... ២

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ...... ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...... ២

**ជំពូកទី ១**

**សញ្ញាណទូទៅនៃអំណាចមេបា**

**ផ្នែកទី១៖ និយមន័យនៃអំណាចមេបា** ...... ៣

**ផ្នែកទី២៖ ការទទួលស្គាល់ និងការបដិសេធអំណាចមេបា** ...... ៣

កថាខណ្ឌទី១៖ ការទទួលស្គាល់អំណាចមេបា ...... ៣

១. ចំពោះកូនបង្កើត ...... ៣

១.១. មាតុភាព ...... ៣

១.២. បិតុភាព ...... ៤

២. ចំពោះកូនសុំ ...... ៥

២.១. កូនសុំធម្មតា ...... ៥

២.២. កូនសុំពេញលេញ ...... ៥

កថាខណ្ឌទី២៖ ការបដិសេធអំណាចមេបា ...... ៦

១. ការបដិសេធបិតុភាពពីជនដែលសន្មតថាជាឪពុក ...... ៦

២. ការបដិសេធបិតុភាពពីកូន ...... ៧

**ផ្នែកទី៣៖ ការកំណត់អ្នកមានអំណាចមេបា** ...... ៧

កថាខណ្ឌទី១៖ ករណីមានចំណងអាពាហ៍ពិពាហ៍ ...... ៧

១. ករណីឪពុកម្ដាយមិនលែងលះគ្នា......8
២. ករណីឪពុកម្ដាយលែងលះគ្នា......8
២.១. ការផ្ដល់អំណាចមេបាដោយមានការព្រមព្រៀង......៩
២.២. ការផ្ដល់អំណាចមេបាដោយមិនមានការព្រមព្រៀង......៩
កថាខណ្ឌទី២៖ ករណីគ្មានចំណងអាពាហ៍ពិពាហ៍ (អនីតិសង្វាស)......១០

## ជំពូកទី២

## សិទ្ធិ ភារកិច្ច និងករណីយកិច្ច របស់អ្នកមានអំណាចមេបា

**ផ្នែកទី១៖ សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងកូន**......១១
កថាខណ្ឌទី១៖ ការចិញ្ចឹមបីបាច់ថែរក្សាកូន......១១
កថាខណ្ឌទី២៖ ការអប់រំកូន......១១
កថាខណ្ឌទី៣៖ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់កូន......១២
កថាខណ្ឌទី៤៖ការគ្រប់គ្រងទ្រព្យសម្បត្តិកូន......១៣
កថាខណ្ឌទី៥៖ ការទាមទាឱ្យប្រគល់កូន......១៤
**ផ្នែកទី២៖ សិទ្ធិ និងករណីយកិច្ចរបស់អ្នកពុំមានអំណាចមេបា**......១៥
កថាខណ្ឌទី១៖ ការចូលជួប ឬប្រាស្រ័យទាក់ទងជាមួយកូន និងការទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់គ្រប់គ្រងថែរក្សាកូន......១៦
កថាខណ្ឌទី២៖ ការទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន......១៧
**ផ្នែកទី៣៖ អាហារកាតព្វកិច្ច**......១៧
កថាខណ្ឌទី១៖ ការផ្គត់ផ្គង់អាហារកាតព្វកិច្ច......១៨
១. បុគ្គលផ្គត់ផ្គង់អាហារកាតព្វកិច្ច......១៨
២. បុគ្គលដែលទទួលបានអាហារកាតព្វកិច្ច (កូន)......១៩
៣. ការកំណត់សោហ៊ុយចំណាយ ចំពោះការផ្គត់ផ្គង់កូនជាអនីតិជន......២០
កថាខណ្ឌទី២៖ ការផ្លាស់ប្ដូរ ឬការលុបចោលនៃអាហារកាតព្វកិច្ច......២១

## ជំពូកទី៣

## ការផ្លាស់ប្ដូរអ្នកមានអំណាចមេបា

**ផ្នែកទី១៖ ការបំពានករណីកិច្ចជាអ្នកមានអំណាចមេបា**......២២

កថាខណ្ឌទី១៖ ការព្យួរ ឬការដកហូតអំណាចមេបា....................................................................២២
កថាខណ្ឌទី២៖ ការលុបចោលការប្រកាសព្យួរ និងការដកហូតអំណាចមេបា ....................................២៣
កថាខណ្ឌទី៣៖ ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា.............................................២៣
កថាខណ្ឌទី៤៖ អ្នកមានអំណាចមេបាទទួលមរណៈភាព ...........................................................២៥
**ផ្នែកទី២៖ ការព្យួរ និងការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ** .... ២៦
**ផ្នែកទី៣៖ ការបញ្ចប់អំណាចមេបា**........................................................................ ២៨
**សេចក្ដីសន្និដ្ឋាន** ........................................................................................... ៣១
**អនុសាសន៍** ..................................................................................................៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១ . លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅនៅក្នុងសង្គមរស់នៅសព្វថ្ងៃ នៅពេលដែលបុគ្គលពីរនាក់បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាំអោយចំណងអាពាហ៍ពិពាហ៍ក្លាយជាមូលដ្ឋានចម្បង ធ្វើអោយប្តីប្រពន្ធមានទំនាក់ទំនងគតិយុត្តរវាងគ្នានឹងគ្នា ហើយអាចបង្កើតជាក្រុមគ្រួសារជាមួយគ្នាបានតាមក្បួនច្បាប់។ ទន្ទឹមនឹងនេះក៏មានគ្រួសារខ្លះមិនបានកើតឡើងដោយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេទោះបីជាមាននាមជាគ្រួសារក៏ដោយដែលតាមសន្ទានុក្រមច្បាប់ថា អនីតិសង្វាស។ពាក្យថាគ្រួសារមានតែប្តីប្រពន្ធពុំមានលក្ខណៈពេញលេញនោះទេលុះត្រាតែអាចមានចំណងអ្វីមួយមកបំពេញបន្ថែមក្នុងចន្លោះដែលខ្វះខាតនោះអោយមានភាពគ្រប់គ្រាន់ក្នុងពាក្យថាគ្រួសារនោះគឺជា កូន។ កូនជាហេតុដែលផ្សារភ្ជាប់នូវទំនាក់ទំនងប្តីប្រពន្ធអោយកាន់តែមានភាពល្អប្រសើរឡើង ទើបក្នុងក្រមរដ្ឋប្បវេណីមានចែងពាក់ព័ន្ធពីទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ជាគោលការណ៍ឪពុកម្តាយគឺជាអ្នកមានសិទ្ធិអំណាចមេបាលើកូន ឪពុកម្តាយមានករណីកិច្ចប្រើប្រាស់អំណាចមេបាដោយសហការគ្នា។ផ្ទុយទៅវិញប្រសិនបើចំណងអាពាហ៍ពិពាហ៍របស់ឪពុកម្តាយបានរលាយ នាំអោយមានការកំណត់អ្នកដែលមានអំណាចមេបាលើកូនដោយត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបាលើកូន។នៅក្នុងករណីខ្លះអ្នកដែលមានអំណាចមេបាក៏អាចមិនមែនជាឪពុកម្តាយបង្កើតដែរពោលគឺអាចជាបុគ្គលផ្សេងទៀតដូចជាឪពុកម្តាយចិញ្ចឹមក៏អាចមានសិទ្ធិអំណាចមេបាមកលើកូនផងដែរ។រីឯក្នុងករណីមួយចំនួនទៀត ដែលឪពុកម្តាយបានប្រើប្រាស់សិទ្ធិអំណាចមេបានោះហួសហេតុ ដើម្បីការពារផលប្រយោជន៍របស់កូនសិទ្ធិអំណាចមេបានេះក៏អាចព្យួរ ឬដកហូតបានដែរ។

## ២ . ចំណោទបញ្ហានៃការស្រាវជ្រាវ

តើអំណាចមេបាគឺជាអ្វី? បុគ្គលណាខ្លះដែលមានសិទ្ធិទទួលអំណាចមេបាបាន? ក្នុងករណីឪពុកម្តាយលែងលះគ្នា តើការកំណត់អំណាចមេបាត្រូវធ្វើឡើងដូចម្តេច? ហើយអ្នកដែលមានសិទ្ធិអំណាចមេបា និងអ្នកគ្មានសិទ្ធិអំណាចមេបាមានសិទ្ធិនិងករណីកិច្ចអ្វីខ្លះ? ក្នុងករណីដែលអ្នកដែលមានអំណាចមេបាគាត់បានបំពានសិទ្ធិ ឬករណីកិច្ចអំណាចមេបាទៅលើកូន តើតុលាការមាននីតិវិធី ឬយុទ្ធសាស្ត្រយ៉ាងដូចម្តេចចំពោះជននោះ?

## ៣ . គោលបំណងនៃការសិក្សាស្រាវជ្រាវ

ចំពោះគោលបំណងដែលយើងខ្ញុំទាំងពីរនាក់សម្រេចចិត្ត និងចាប់ផ្តើមតាក់តែងនូវសារណានេះឡើងគឺដើម្បីស្វែងយល់អោយបានជាក់លាក់ និងកាន់តែស៊ីជម្រៅទៅលើប្រធានបទក៏ដូចជាបន្ថែមនូវចំណេះដឹងផ្ទាល់ខ្លួននានាអំពីមូលហេតុ និងនីតិវិធីក្នុងការកំណត់អំណាចមេបាមួយកម្រិតទៀត។ ម្យ៉ាងវិញទៀតសារណានេះក៏ជាឯកសារមួយសម្រាប់តម្កល់ទុកនៅក្នុងសាកលវិទ្យាល័យ ដើម្បីឱ្យនិស្សិតជំនាន់ក្រោយបានសិក្សាស្វែងយល់

បន្ថែមទៀតការធ្វើបែបនេះដើម្បីជាការចូលរួមចំណែកក្នុងការលើកស្ទួយវិស័យគតិយុត្តនៅក្នុងប្រទេសកម្ពុជាក្នុងនាមយើងខ្ញុំទាំងពីរនាក់ជានិស្សិតផ្នែកនីតិសាស្ត្រនេះផ្ទាល់។

## ៤ . ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទបញ្ចប់ការសិក្សាមួយនេះ គឺសិក្សាទៅលើលក្ខណៈទូទៅអំពីបុគ្គលដែលមានសិទ្ធិទទួលបានអំណាចមេបា, សិទ្ធិ កាតព្វកិច្ច ករណីកិច្ចរបស់អ្នកដែលមានអំណាចមេបា និងអ្នកពុំមានអំណាចមេបា, និងការផ្លាស់ប្តូរអំណាចមេបាតែប៉ុណ្ណោះ។ បន្ថែមពីលើនេះការស្រាវជ្រាវរបស់យើងខ្ញុំគឺផ្អែកសំខាន់តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា(២០០៧)ដែលជាឯកសារគោល និងបានដកស្រង់ចេញពីសៀវភៅដែលមានខ្លឹមសារល្អៗមួយចំនួនរបស់សាស្ត្រាចារ្យ មេធាវី ចៅក្រម និងអ្នកអនុវត្តច្បាប់នានាដែលទាក់ទងទៅនឹងអំណាចមេបា។

## ៥ . សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់បន្ទាប់ពីការសិក្សាស្រាវជ្រាវនេះត្រូវបានបញ្ចប់ ឯកសារដែលជាសារណាមួយនេះអាចផ្តល់ជាប្រយោជន៍ដល់អ្នកដែលសិក្សាផ្នែកនីតិសាស្ត្រ និងអ្នកគ្រប់មជ្ឈដ្ឋានទាំងអស់ដែលមានបំណងចង់សិក្សាស្វែងយល់បន្ថែមលើប្រធានបទនេះបានបង្កើននូវចំណេះដឹងផ្ទាល់ខ្លួន ក៏ដូចជានាំអោយយើងខ្ញុំទាំងពីរនាក់បានយល់កាន់តែច្បាស់ និងស៊ីជម្រៅទៅលើមូលដ្ឋានច្បាប់ដែលទាក់ទងនឹងអំណាចមេបានេះផងដែរ។

## ៦ . វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវមួយនេះ យើងខ្ញុំមានការពន្យល់បកស្រាយទ្រឹស្តី លើកទល្លីករណ៍មកបញ្ជាក់តាមរយៈការប្រមូលទិន្នន័យពីការបកស្រាយពន្យល់ណែនាំពីលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យផ្នែកច្បាប់ ជាពិសេសលោកគ្រូសាស្ត្រាចារ្យណែនាំប្រធានបទសារណាយើងខ្ញុំផ្ទាល់។ ក្នុងខ្លឹមសារនេះផងដែរយើងខ្ញុំយកចេញនូវគោលគំនិតពីក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សេចក្តីកំណត់នៃក្រមរដ្ឋប្បវេណី សេចក្តីពន្យល់ពីក្រមរដ្ឋប្បវេណីជាគោល និងឯកសារផ្សេងៗមួយចំនួនទៀតពីបណ្ណាល័យ ពីសៀវភៅរបស់សាស្ត្រាចារ្យ អ្នកនិពន្ធជាច្រើនផងដែរ ហើយនៅក្នុងសារណានេះក៏មានភ្ជាប់នូវគំរូសាលក្រមមួយចំនួន និងឧបសម្ព័ន្ធជាច្រើនទៀត។

## ៧ . រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើការបកស្រាយទៅលើសារណាមួយនេះ អោយកាន់តែច្បាស់លាស់ និងស៊ីជម្រៅ យើងខ្ញុំបានធ្វើការបែងចែក ជាបីចំណុចធំៗគឺ៖

- ជំពូកទី១៖ សញ្ញាណទូទៅនៃអំណាចមេបា។
- ជំពូកទី២៖ សិទ្ធិ កាតព្វកិច្ច និងករណីកិច្ច របស់អ្នកមានអំណាចមេបា។
- ជំពូកទី៣៖ ការផ្លាស់ប្តូរអ្នកមានអំណាចមេបា។

# ជំពូកទី១
# សញ្ញាណទូទៅ
# នៃអំណាចមេធា

# ជំពូកទី១
# សញ្ញាណទូទៅនៃអំណាចមេបា

ជាទូទៅអ្នកដែលមានអំណាចមេបាទៅលើអនីតិជនបានគឺមានតែឪពុកម្តាយបង្កើតប៉ុណ្ណោះដែលមានករណីកិច្ចចិញ្ចឹមបីបាច់ ថែរក្សា និងគ្រប់គ្រងកូនបាន។ទោះបីកូនជាអនីតិជនក៏ដោយក៏មានករណីខ្លះអ្នកដែលមានអំណាចមេបា គឺមិនមែនជាឪពុកម្តាយបង្កើតនោះទេតែអាចជាបុគ្គលផ្សេងទៀតដូចជា ឪពុកម្តាយចិញ្ចឹមក៏អាចមានសិទ្ធិអំណាចមេបាមកលើកូនបានដូចគ្នា។មិនត្រឹមតែប៉ុណ្ណោះក្នុងច្បាប់ក៏បានបែងចែកអំពីការកំណត់អំណាចមេបាផងដែរ ដោយការកំណត់អ្នកដែលមានអំណាចមេបានេះមានដូចជា ការកំណត់អំណាចមេបាក្នុងករណីមានចំណងអាពាហ៍ពិពាហ៍ ការកំណត់អំណាចមេបាក្នុងករណីឪពុកម្តាយលែងលះគ្នា និងការកំណត់អំណាចមេបាក្នុងករណីម្តាយឪពុកគ្មានចំណងអាពាហ៍ពិពាហ៍។

## ផ្នែកទី១៖ និយមន័យនៃអំណាចមេបា

នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចែងថាអំណាចមេបា គឺសំដៅដល់អ្នកដែលមានសិទ្ធិ និងករណីកិច្ច ត្រូវបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។[1] ក្នុងអត្ថន័យនេះបានន័យថាអំណាចមេបា គឺផ្តើមចេញពីទំនាក់ទំនងរវាងឪពុកម្តាយ និងកូនដែលមាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។[2]

## ផ្នែកទី២៖ ការទទួលស្គាល់ និងការបដិសេធអំណាចមេបា

### កថាខណ្ឌទី១៖ ការទទួលស្គាល់អំណាចមេបា

ការទទួលស្គាល់ គឺជាវិធីមួយដើម្បីបង្កើតទំនាក់ទំនងញាតិរវាងឪពុក ម្តាយ និងកូន។ការទទួលស្គាល់គឺជាការបង្ហាញឆន្ទៈរបស់ឪពុកម្តាយទទួលស្គាល់កូនបង្កើតរបស់ខ្លួន។

#### ១. ចំពោះកូនបង្កើត

ជាធម្មតាអ្នកដែលមានអំណាចមេបា គឺជាឪពុកម្តាយបង្កើត។ឪពុកម្តាយត្រូវមានទំនួលខុសត្រូវក្នុងការចិញ្ចឹមថែរក្សា អប់រំកូន ចាប់តាំងពីកូនចាប់កំណើតក្នុងផ្ទៃរហូតដល់កូនគ្រប់នីតិភាព។

##### ១.១. មាតុភាព

មាតុភាពត្រូវបានគេកំណត់ដោយការសម្រាលកូនមានន័យថាស្ត្រីដែលបានសម្រាលកូនគឺជាម្តាយរបស់កូន។[3] ហេតុដូចនេះហើយការបង្កើតអោយមានមាតុភាពដោយផ្អែកលើអង្គហេតុស្តីពីការសម្រាលកូនជាអង្គហេតុ

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៤។
[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៤៧ វាក្យខណ្ឌទី១។
[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៨៧។

បញ្ជាក់ពីវត្តមានរបស់ម្តាយមានភាពច្បាស់លាស់ និងជាក់ស្តែងនាំអោយមានការកំណត់មាតុភាពព្រមគ្នាជាមួយនឹងកំណើតរបស់កូន។ដូច្នេះប្រសិនបើស្ត្រីដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍បានផ្តល់កំណើតអោយកូន ស្ត្រីនោះក៏ក្លាយជាអ្នកដែលមានអំណាចមេបាលើកូននោះផងដែរ។

### ១.២. បិតុភាព

បិតុភាពត្រូវបានគេកំណត់ដោយការសន្មត ហើយអាចអនុវត្តបានតែនៅក្នុងករណីប្តីប្រពន្ធមានចំណងអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ ឯករណីអនីតិសង្វាសមិនអាចកំណត់បិតុភាពតាមការសន្មតបានទេ។ បិតុភាពនៅក្នុងករណីអនីតិសង្វាសត្រូវបានបង្កើតឡើងតាមរយៈការទទួលស្គាល់ ទោះបីជាធាតុពិតមានទំនាក់ទំនងឈាមជ័រជាឪពុក និងកូនបង្កើតក៏ដោយ ប្រសិនបើគ្មានការទទួលស្គាល់ទេកូននោះមិនចាត់ទុកថាជាកូនរបស់ឪពុកតាមផ្លូវច្បាប់ទេ។ទារកនៅក្នុងគត៌ប្រពន្ធដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវសន្មតថាជាកូនរបស់ប្តី។[4] កូនដែលបានកើតនៅក្រោយអំឡុងពេល១៨០(មួយរយប៉ែតសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើតឡើង ត្រូវសន្មតថាមានគត៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍។[5] ដោយសារតែការរីកចម្រើននៃផ្នែកវេជ្ជសាស្ត្រក្នុងការថែទាំទារក ទារកដែលកើតក្រោយពេលមានផ្ទៃពោះប្រាំខែក៏អាចរស់រានមានជីវិតដែរមានន័យថាក្រោយពេលរៀបអាពាហ៍ពិពាហ៍ភ្លាមម្តាយមានផ្ទៃពោះភ្លាមៗ ហើយកូននោះកើតមុនកាលកំណត់ហួសហេតុក្នុងកំឡុងពេល១៨០ថ្ងៃគិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍។ ឧទាហរណ៍៖ ប្រពន្ធរបស់ខ្លួនមានផ្ទៃពោះតាំងពីមុនថ្ងៃរៀបអាពាហ៍ពិពាហ៍បន្ទាប់មកប្តីបានដឹង និងព្រមទទួលស្គាល់ថាខ្លួនជាឪពុករបស់កូន នោះកូននឹងចាត់ទុកថាជាកូនរបស់ប្តីនោះ។ ម្យ៉ាងទៀតកូនដែលកើតក្នុងកំឡុងពេល៣០០(បីរយ)ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយឬលុបចោលអាពាហ៍ពិពាហ៍ ក៏ត្រូវបានសន្មតថាមានគត៌នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ដែរ។ នៅក្នុងករណីម្តាយរៀបអាពាហ៍ពិពាហ៍ថ្មី ប្រសិនបើម្តាយបានគោរពចិរវេលា១២០(មួយរយម្ភៃ)ថ្ងៃដូចការកំណត់របស់ច្បាប់ ហើយកូនបានកើតក្រោយអំឡុងពេល១៨០ថ្ងៃគិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ថ្មីកូននោះជាកូនរបស់ប្តីក្រោយ។ ឧទាហរណ៍៖ A និង B បានលែងលះគ្នានៅថ្ងៃទី០៩/០៩/២០២២ ហើយ B បានរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយC នៅថ្ងៃទី០២/០២/២០២៣ Bបានសម្រាលD នៅថ្ងៃទី០៩/១១/២០២៣ ករណីនេះDជាកូនរបស់C។ ប៉ុន្តែក្នុងករណីម្តាយរៀបអាពាហ៍ពិពាហ៍ថ្មី ដោយមិនគោរពតាមច្បាប់កំណត់១២០ថ្ងៃ៖

- ប្រសិនបើកូនកើតក្រោយអំឡុងពេល១៨០ថ្ងៃគិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ថ្មីកូននោះជាកូនរបស់ប្តីក្រោយ។ ឧទាហរណ៍៖ A និង B លែងលះនៅថ្ងៃទី០៩/០៩/២០២២, Bបានរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយC នៅថ្ងៃទី០១/១២/២០២២, Bបានសម្រាលD នៅថ្ងៃទី១៩/០៧/២០២៣, Dគឺជាកូនរបស់C។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៨៨ កថាខណ្ឌទី១។

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៨៨ កថាខណ្ឌទី២។

- ប្រសិនបើកូនបានកើតក្នុងអំឡុងពេល៣០០ថ្ងៃ គិតចាប់ពីថ្ងៃរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ និងក្នុងអំឡុងពេល១៨០ថ្ងៃ គិតចាប់ពីថ្ងៃរៀបអាពាហ៍ពិពាហ៍ថ្មី នោះនឹងមានស្ថានភាពជាន់គ្នា អាចជាកូនរបស់ប្តីមុន និងអាចជាកូនរបស់ប្តីក្រោយ ក្នុងករណីនេះច្បាប់សម្មតថាជាកូនរបស់ប្តីក្រោយ។[6]

**២. ចំពោះកូនសុំ**

សុំកូន គឺជាការសុំយកកូនរបស់អ្នកដទៃយកមកចិញ្ចឹមដោយស្របច្បាប់ និងបង្កើតទំនាក់ទំនងញាតិរវាងឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម និងកូនចិញ្ចឹម ឲ្យមានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតដែរ។នៅក្នុងរបបសុំកូនមានពីរប្រភេទគឺ ការសុំកូនធម្មតា និងការសុំកូនពេញលេញ។ហើយអ្នកដែលមានអំណាចមេបាលើកូនសុំគឺឪពុកម្តាយចិញ្ចឹម។[7]

**២.១. កូនសុំធម្មតា**

សុំកូនធម្មតា គឺជាការសុំកូនមួយប្រភេទដែលញាតិភាពរវាងឪពុកម្តាយបង្កើតនិងកូនសុំត្រូវបន្តអត្ថិភាព ហើយកូនសុំនិងឪពុកម្តាយចិញ្ចឹមមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក។[8] ដូចនេះហើយវាមានភាពចាំបាច់ក្នុងការសម្រេចថាតើឪពុកម្តាយបង្កើតឬឪពុកម្តាយចិញ្ចឹមជាអ្នកដែលមានអំណាចមេបា។ បើសុំកូនដែលជាអនីតិជនមានគោលបំណងយកកូននោះទៅចិញ្ចឹមបីបាច់មើលថែរក្សាដោយផ្ទាល់ ហេតុនេះហើយឪពុកម្តាយចិញ្ចឹម ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមគួរជាអ្នកដែលមានអំណាចមេបាទើបគាត់អាចអនុវត្តសិទ្ធិរបស់គាត់បានពេញលេញ ហើយកូនក៏អាចទទួលបានផលប្រយោជន៍របស់ខ្លួនបានគ្រប់គ្រាន់។[9] ប៉ុន្តែក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬម្តាយចិញ្ចឹម និងសហព័ទ្ធនោះ។ ម្យ៉ាងទៀតកូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន។[10] ហើយកូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើត ទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ។

**២.២. កូនសុំពេញលេញ**

ជាគោលការណ៍នៃការសុំកូនពេញលេញ កូនសុំត្រូវមានអាយុតិចជាងប្រាំបីឆ្នាំ។[11]សុំកូនពេញលេញត្រូវបញ្ចប់ញាតិភាពរួមទាំងសិទ្ធិ និងកាតព្វកិច្ចរវាងកូនសុំ និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលនៃកូននោះដោយបង្កើតទំនាក់ទំនងញាតិជាមួយឪពុកម្តាយចិញ្ចឹមវិញ មានន័យថាញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតព្រម

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៨៨ កថាខណ្ឌទី៣។
[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៥។
[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៦ កថាខណ្ឌទី១។
[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០២៧ កថាខណ្ឌទី៣ វាក្យខណ្ឌទី១។
[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០២៧ កថាខណ្ឌទី២។
[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០១០។

ទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះត្រូវបញ្ចប់ដោយសុំកូនពេញលេញ។[12] ហើយការសុំកូននេះត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់។ ម្យ៉ាងទៀតនៅក្នុងករណីសុំកូនពេញលេញដោយសារតែទំនាក់ទំនងគតិយុត្តរវាងឪពុកម្តាយបង្កើត និងកូនសុំត្រូវបានកាត់ផ្តាច់ ដូច្នេះមានតែឪពុកម្តាយចិញ្ចឹមទេដែលក្លាយជាឪពុកម្តាយរបស់កូននោះ ហេតុនេះហើយឪពុកម្តាយចិញ្ចឹមក្លាយជាអ្នកដែលមានអំណាចមេបា។[13]កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន។[14] ហើយកូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតទទួលបានសិទ្ធិ និងករណីកិច្ចដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ។

**កថាខណ្ឌទី២៖ ការបដិសេធអំណាចមេបា**

បិតុភាពត្រូវបានសន្មតនៅក្នុងច្បាប់ ប៉ុន្តែប្រសិនបើការសន្មតនោះផ្ទុយពីការពិតជនដែលត្រូវបានសន្មតថាជាឪពុកឬកូនអាចបដិសេធបិតុភាពបាន។[15] ឯការបដិសេធបិតុភាពអាចធ្វើឡើងដោយឪពុកហៅថាបណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក។[16] ការបដិសេធបិតុភាពដែលធ្វើឡើងដោយកូនហៅថាបណ្តឹងបដិសេធបិតុភាពពីកូន។[17] ការបដិសេធបិតុភាពនេះត្រូវបង្កើតអានុភាពប្រតិសកម្មតាំងពីពេលកំណើតរបស់កូន។

**១. ការបដិសេធបិតុភាពពីជនដែលសន្មតថាជាឪពុក**

សិទ្ធិបដិសេធបិតុភាពរបស់ជនដែលត្រូវបានសន្មតថាជាឪពុកត្រូវអនុវត្តដោយបណ្តឹងចំពោះកូនតាមការប្តឹងបដិសេធបិតុភាពដោយអះអាងថាមិនមានបិតុភាពពិតប្រាកដរវាងឪពុក និងកូន។ ក្នុងករណីជនសន្មតថាជាឪពុកបានទទួលមរណៈភាពមុនកំណើតកូន ឬក្នុងករណីដែលជននោះបានទទួលមរណៈភាពក្នុងអំឡុងពេលដែលខ្លួនអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពតែមិនបានដាក់ពាក្យបណ្តឹងបដិសេធ ហើយជនដែលត្រូវបានបំពានសិទ្ធិសន្តតិកម្មដោយសារកូននោះ ឬញាតិលោហិតក្នុង៣(បី)ថ្នាក់ របស់ជនដែលត្រូវបានសន្មតថាជាឪពុកអាចដាក់ពាក្យបណ្តឹងបដិសេធបាន។ ពេលដែលអាចដាក់ពាក្យបណ្តឹងបដិសេធបិតុភាពគឺអំឡុងពេលប្រាំមួយខែគិតចាប់ពីពេលដែលខ្លួនបានដឹងពីកំណើតកូន។[18] នៅពេលដែលអំឡុងពេលដែលបានកំណត់បានកន្លងផុតទៅ

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០១៤ វាក្យខណ្ឌទី១។
[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០១៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី១។
[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០១៥ កថាខណ្ឌទី២។
[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៨៩។
[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៩០។
[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៩១។
[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៩០ កថាខណ្ឌទី២។

ហើយជនដែលបានសន្មតថាជាឪពុកជាជនដែលនៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេលនោះគេត្រូវគណនាដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ។[19]

### ២. ការបដិសេធបិតុភាពពីកូន

សិទ្ធិបដិសេធបិតុភាពរបស់កូន ត្រូវអនុវត្តដោយបណ្ដឹងចំពោះជនដែលត្រូវបានសន្មតថាជាឪពុក។ក្នុងករណីដែលការបដិសេធបិតុភាពរបស់កូនត្រូវអនុវត្តចំពោះជនដែលជាឪពុកបានក៏ដោយ ប៉ុន្តែដោយសារតែកូនជាអនីតិជនជាអ្នកប្រើសិទ្ធិបដិសេធ ហើយគ្មានអ្នកដែលអនុវត្តអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវជ្រើសរើសអ្នកតំណាងពិសេស។[20] ក្នុងករណីកូនទទួលមរណៈភាពមុនដាក់ពាក្យបណ្ដឹង បច្ឆាញាតិផ្ទាល់របស់ជននោះអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបាន។ ប៉ុន្តែបើករណីកូនបានទទួលមរណៈភាពក្រោយដាក់ពាក្យបណ្ដឹងបច្ឆាញាតិផ្ទាល់របស់កូនអាចបន្តនីតិវិធីបណ្ដឹងបាន។យើងអាចនិយាយបានថាបណ្ដឹងបដិសេធបិតុភាពអាចធ្វើឡើងដោយកូនក៏ដោយ ក៏វាមិនមែនជាការប្រសើរទេដែលអនុញ្ញាតឱ្យកូនអាចដាក់ពាក្យបណ្ដឹងបដិសេធបិតុភាពបានរហូតនោះ កូនមិនអាចអនុវត្តសិទ្ធិបដិសេធបានឡើយប្រសិនបើអំឡុងពេល៦(ប្រាំមួយ)ខែបានកន្លងផុតគិតចាប់ពីពេលខ្លួនបានក្លាយជានីតិជន។[21] នៅពេលដែលអំឡុងពេលដែលបានកំណត់បានកន្លងផុត ហើយកូនជាជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅអំឡុងពេលនោះត្រូវគណនាដោយគិតចាប់ពីពេលដែលមានការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ។

## ផ្នែកទី៣៖ ការកំណត់អ្នកមានអំណាចមេបា

ជាគោលការណ៍ឪពុកម្តាយគឺជាអ្នកដែលមានសិទ្ធិអំណាចមេបាលើកូន ហើយឪពុកម្តាយត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នាចំពោះកូនដែលជាអនីតិជន។ផ្ទុយទៅវិញប្រសិនបើចំណងអាពាហ៍ពិពាហ៍របស់ឪពុកម្តាយបានរលាយ នោះនឹងនាំអោយមានការកំណត់អ្នកដែលមានអំណាចមេបាលើកូនដោយកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបាលើកូន។ការកំណត់អំពីអ្នកមានអំណាចមេបាអាចកើតឡើងក្នុងករណីដែលឪពុកម្តាយមានចំណងអាពាហ៍ពិណាហ៍ ឬករណីឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍។

### កថាខណ្ឌទី១៖ ករណីមានចំណងអាពាហ៍ពិពាហ៍

ឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ សំដៅដល់ឪពុកម្តាយដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ ឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នាចំពោះកូន។កូនដែលសន្មតថាកើតនៅក្នុងចំណងអាពាហ៍ពិពាហ៍ គឺម្តាយនៃកូនមានគត៌ក្នុងរយៈពេលដែលឪពុកម្តាយនៅជាប់

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា២៤។

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៩១ កថាខណ្ឌទី២។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៩៩១ កថាខណ្ឌទី៣។

ចំណងអាពាហ៍ពិពាហ៍នឹងគ្នា មានន័យថាកូនដែលបានកើត១៨០(មួយរយប៉ែតសិប)ថ្ងៃយ៉ាងតិចក្រោយថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬក្នុងរយៈពេល៣០០(បីរយ)ថ្ងៃ គិតពីថ្ងៃដាច់ចំណងអាពាហ៍ពិពាហ៍។ ក្នុងករណីដែលឪពុក ឬម្តាយមិនអាចប្រើប្រាស់អំណាចមេបាដោយសហការគ្នាបានដោយសារតែឪពុក ឬក៏ម្តាយ បាត់បង់សតិ បាត់ខ្លួន ឬមិនអាចទាក់ទងបានទេនោះឪពុក ឬម្តាយ ម្ខាងទៀតអាចប្រើប្រាស់អំណាចមេបានោះបាន។

### ១. ករណីឪពុកម្តាយមិនលែងលះ

ឪពុកម្តាយមានចំណងអាពាហ៍ពិពាហ៍ ត្រូវអនុវត្តអំណាចមេបាចំពោះកូនជាអនីតិជនដោយសហការគ្នា[22]។ មានន័យថារាល់ការគ្រប់គ្រងទ្រព្យសម្បត្តិកូន ការចិញ្ចឹមបីបាច់ថែរក្សា ឬសកម្មភាពតំណាងអោយកូនគឺត្រូវធ្វើឡើងដោយមានការសម្រេចចិត្តទាំងពីរនាក់ ទាំងឪពុកទាំងម្តាយ មិនមែនសម្រេចចិត្តតែម្ខាងណាទេ។ ប៉ុន្តែនៅក្នុងស្ថានភាពដែលឪពុក ឬម្តាយណាម្នាក់មិនអាចអនុវត្តលើអំណាចមេបាបាននោះនាំអោយការសម្រេចអាចធ្វើឡើងបានតាមការសម្រេចរបស់ឪពុក ឬម្តាយដែលអាចអនុវត្តលើអំណាចមេបាតែម្នាក់បាន បើទោះបីជាស្ថិតក្នុងអំណាចមេបារួមក៏ដោយ។

### ២. ករណីឪពុកម្តាយលែងលះគ្នា

ការលែងលះគ្នា គឺការផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់ប្តីប្រពន្ធដែលបានរៀបការពេញច្បាប់។ នៅពេលដែលឪពុកម្តាយលែងលះគ្នាជាធម្មតាឪពុកម្តាយនឹងរស់នៅបែកគ្នា ដូច្នេះកូនត្រូវរស់នៅជាមួយឪពុក ឬម្តាយណាម្ខាង។ ក្នុងករណីដែលឪពុកម្តាយបានលែងលះគ្នាមុនកំណើតកូនអ្នកមានអំណាចមេបាចំពោះកូនគឺម្តាយព្រោះតាមគោលការណ៍កូនដែលនៅបំបៅដោះត្រូវបានទៅម្តាយ ប៉ុន្តែក្រោយកំណើតកូនអាចផ្លាស់ប្តូរទៅឪពុកបានផ្អែកតាមការពិភាក្សាគ្នា។ ប៉ុន្តែបើឪពុកម្តាយលែងលះក្រោយកំណើតកូនអ្នកមានអំណាចមេបាអាចជាឪពុក ឬម្តាយណាម្ខាងផ្អែកតាមការពិភាក្សាគ្នា ប៉ុន្តែបើការពិភាក្សាពុំបានសម្រេចនោះទេតុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន។[23] ដោយឡែកទោះបីជាក្នុងកម្មវត្ថុនៃពាក្យបណ្តឹងលែងលះគ្មានការស្នើសុំឲ្យតុលាការសម្រេចអំពីអំណាចមេបាក៏ដោយ ក៏តុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីអ្នកមានអំណាចមេបាដោយឆន្ទានុសិទ្ធិដែរ ហើយបើគូភាគីមានពាក្យស្នើសុំតុលាការត្រូវធ្វើការសម្រេចសេចក្តីអំពីការចាត់ចែងទាក់ទងនឹងការបីបាច់ថែរក្សាកូន ឬការចាត់ចែងទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិដោយផ្អែកលើផលប្រយោជន៍ និងគិតដល់សុខុមាលភាពរបស់កូនជាធំ។[24]

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៦។

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី៣។

[24] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨ មិថុនា ២០១០, មាត្រាទី២២ កថាខណ្ឌទី១។

### ២.១. ការផ្តល់អំណាចមេបាដោយមានការព្រមព្រៀង

ក្នុងប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា ចំពោះករណីដែលឪពុកម្តាយលែងលះគ្នាគេត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបាតាមការពិភាក្សារបស់ឪពុកម្តាយនោះ។[25] ការសម្រេចអ្នកដែលត្រូវមានអំណាចមេបាតាមការព្រមព្រៀងរបស់ឪពុកម្តាយពុំមានការបង្ខិតបង្ខំដល់ភាគីម្ខាងណាឡើយក្នុងការទទួលយកកូនឱ្យមកស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។ សេចក្តីសម្រេចអំពីអ្នកមានអំណាចមេបាអាចធ្វើឡើងតាមសាលក្រម ឬដីកាសម្រេចដោយផ្អែកតាមការលែងលះរបស់ឪពុកម្តាយ។ មានន័យថាប្រសិនបើឪពុកម្តាយបានព្រមព្រៀងគ្នាទាំងរឿងលែងលះ និងកំណត់អ្នកដែលត្រូវមានអំណាចមេបាលើកូន ភាគីដែលដាក់ពាក្យសុំធ្វើការព្រមព្រៀងគ្នាត្រូវកំណត់សរសេរនៅក្នុងពាក្យសុំលែងលះនោះតែម្តង ដើម្បីសុំអោយតុលាការធ្វើការសម្រេចតាមអ្វីដែលសហព័ទ្ធបានព្រមព្រៀងនឹងគ្នា។ ស្ថានភាពនៃការព្រមព្រៀងសម្រេចអ្នកមានអំណាចមេបាពុំមានលក្ខណៈដូចគ្នាទាំងអស់នោះទេ បើភាគីមានការព្រមព្រៀងនាំអោយគ្មានចំណុចវិវាទដូច្នេះតុលាការនឹងធ្វើការសម្រេចតាមការព្រមព្រៀងនោះ។ ប៉ុន្តែបើភាគីមិនមានការព្រមព្រៀងទេនោះតុលាការនឹងធ្វើការសម្រេចដោយឆន្ទានុសិទ្ធិដោយផ្អែកលើប្រយោជន៍របស់កូនជាធំ។

### ២.២. ការផ្តល់អំណាចមេបាដោយមិនមានការព្រមព្រៀង

ប្រសិនបើគូភាគីមិនអាចស្វែងរកដំណោះស្រាយតាមរយៈការពិភាក្សាគ្នាបានទេ គឺតុលាការត្រូវកំណត់អ្នកមានអំណាចមេបាដោយពិចារណាលើផលប្រយោជន៍របស់កូន។[26] ក្នុងការសម្រេចនេះជាទូទៅតុលាការតែងតែពិនិត្យមើលទៅលើចំណុចមួយចំនួនដូចជា៖

- **ប្រាក់ចំណូល៖** ថាតើឪពុក ឬម្តាយម្ខាងណា ដែលគាត់មានការងារ ប្រាក់ចំណូលទៀងទាត់ និងសមរម្យដើម្បីធានាដល់ការចិញ្ចឹមបីបាច់ថែរក្សា និងអប់រំកូន។
- **លំនៅដ្ឋាន៖** តើភាគីខាងឪពុក ឬម្តាយណាម្ខាង ដែលគាត់មានលំនៅដ្ឋានច្បាស់លាស់ក្នុងការអោយកូនរស់នៅប្រកបដោយជាសុកភាពជាង? ឬទីលំនៅខាងណា ដែលមានទីតាំងអំណោយផលជាងសម្រាប់ការរៀនសូត្រ ក៏ដូចជាសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់កូន?
- **បុគ្គលិកលក្ខណៈ អាកប្បកិរិយា និងមនោសញ្ចេតនាចំពោះកូន៖** រវាងឪពុកម្តាយ ថាតើមានអ្នកណាធ្លាប់ប្រើអំពើហិង្សាទៅលើកូន? និងអ្នកណាធ្លាប់យកចិត្តទុកដាក់ទៅលើកូនជាង?

បើសិនជាតុលាការមើលឃើញទៅថាឪពុក ឬម្តាយម្ខាងណាគិតតែពីដើរស៊ីផឹក លេងល្បែងស៊ីសងគ្មានគិតគូរធ្វើការរកស៊ី គ្មានផ្ទះសម្បែងត្រឹមត្រូវ ឬក៏ធ្លាប់ប្រើអំពើហិង្សាលើកូន តុលាការនឹងមិនផ្តល់សិទ្ធិអោយ

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី១។
[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី៣។

ទៅឪពុក ឬម្តាយនោះជាអ្នកទទួលសិទ្ធិគ្រប់គ្រងកូនទេ គឺប្រាកដជាត្រូវអោយទៅភាគីម្ខាងទៀតដែលមានប្រាក់ចំណូលការងារត្រឹមត្រូវ មានកន្លែងស្នាក់នៅច្បាស់លាស់ មានអត្តចរិកសមរម្យ និងមានការផ្តល់ការយកចិត្តទុកដាក់ខ្ពស់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន។ ដោយឡែកបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមិនបានកំណត់អំពីមូលដ្ឋានសម្រាប់តុលាការក្នុងការសម្រេចជ្រើសរើសអ្នកដែលមានអំណាចមេបាឡើយ ដូច្នេះដើម្បីសម្រេចកំណត់ថាតើឪពុក ឬម្តាយខាងណាជាអ្នកមានគុណសម្បត្តិគ្រាប់គ្រាន់ក្នុងការធ្វើជាអ្នកមានអំណាចមេបា ដូចនេះតុលាការត្រូវថ្លឹងថ្លែងអំពីលទ្ធភាពរវាងឪពុកម្តាយម្ខាងណាដែលអាចផ្តល់ផលប្រយោជន៍ដល់កូនច្រើនជាងគេ ដោយផ្អែកលើការពិចារណាដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

**កថាខណ្ឌទី២៖ ករណីគ្មានចំណងអាពាហ៍ពិពាហ៍** ( **អនីតិសង្វាស** )

អនីតិសង្វាសត្រូវបានគេផ្តល់និយមន័យអោយគឺជា "ស្ថានភាពរបស់បុរស និងនារីដែលរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធមានខាន់ស្លា ប៉ុន្តែឥតមានសំបុត្រអាពាហ៍ពិពាហ៍ទេ។[27] ដោយសារតែឪពុកម្តាយរស់នៅជាអនីតិសង្វាសមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ដូច្នេះគឺមានតែម្តាយទេដែលមានអំណាចមេបានេះដោយអំណាចមេបាធ្លាក់ទៅលើម្តាយដែលជាអ្នកបង្កើតកូននោះដោយស្វ័យប្រវត្តិ។ តែប្រសិនបើឪពុករបស់កូនធ្វើការទទួលស្គាល់ និងចង់មានអំណាចមេបាមកលើកូនដែលជាអនីតិជននោះឪពុកត្រូវតែមានការពិភាក្សាគ្នាជាមួយម្តាយហើយមានការយល់ព្រមពីម្តាយនោះឪពុកត្រូវទទួលបាននូវអំណាចមេបាទោល តែប្រសិនបើជានៅក្នុងការពិភាក្សានោះមិនមានការយល់ព្រមពីខាងម្តាយទេ ឪពុកអាចដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការទាមទារអោយតុលាការកំណត់នូវអ្នកដែលមានអំណាចមេបាបាន។[28] ម្យ៉ាងទៀតបើទោះជាឪពុកម្តាយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ តែបានទទួលស្គាល់ថាកូនដែលកើតមកនោះជាកូនរបស់ខ្លួននៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានតាមរយៈការធ្វើសំបុត្រកំណើតត្រូវចាត់ទុកឪពុកម្តាយនេះជាឪពុកម្តាយរបស់កូន។ការព្រមទទួលស្គាល់កូនអាចធ្វើនៅពេលមុនចុះសំបុត្រអាពាហ៍ពិពាហ៍ អំឡុងពេលអាពាហ៍ពិពាហ៍ ឬក្រោយពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ហើយអាចអនុវត្តបាននូវអំណាចមេបាដោយសហការគ្នាផងដែរ។

---

[27] សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សន្ទានុក្រមបារាំង ខ្មែរនៃពាក្យច្បាប់ (ភ្នំពេញ៖ ហូណាន ២០០៥), ទំព័រទី២៩

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៨ កថាខណ្ឌទី៣។

# ជំពូកទី២
# សិទ្ធិ ភាតពូកិច្ច និង
# ករណីយកិច្ចរបស់អ្នកមាន
# អំណាចមេបា

# ជំពូកទី២

# សិទ្ធិ ភាតព្វកិច្ច និងករណីយកិច្ច របស់អ្នកមានអំណាចមេបា

## ផ្នែកទី១៖ សិទ្ធិ និងករណីយកិច្ចទាក់ទងនិងកូន

ជាទូទៅនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាអ្នកដែលមានអំណាចមេបាទៅលើអនីតិជនគឺមានឪពុកម្តាយបង្កើត ឬឪពុកម្តាយចិញ្ចឹម ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលដែលតុលាការបានកំណត់តាមរយៈសេចក្តីសម្រេច។ អ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចក្នុងការចិញ្ចឹមបីបាច់ថែរក្សារូបកាយ អប់រំ គ្រប់គ្រងទ្រព្យសម្បត្តិ និងទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់កូនដែលជាអនីតិជននោះរហូតកូនដល់នីតិភាពឱ្យគោរពតាមករណីយកិច្ចដែលច្បាប់បានកំណត់ និងអនុវត្តនូវសិទ្ធិដែលខ្លួនមានក្នុងអំឡុងពេលជាអ្នកមានអំណាចមេបាចំពោះកូនឱ្យបានត្រឹមត្រូវ។

### កថាខណ្ឌទី១៖ ការចិញ្ចឹមបីបាច់ថែរក្សាកូន

ការចិញ្ចឹមបីបាច់ថែរក្សាកូន គឺជាដំណើរការបីបាច់ថែរក្សាកូនតាំងពីកើតរហូតដល់ធំដឹងក្តីព្រោះវាជាកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនអាចខ្វះបាន។ សិទ្ធអំណាចរបស់អ្នកដែលមានអំណាចមេបា ឬរបស់អ្នកអាណាព្យាបាលមិនមានត្រឹមតែចំពោះសកម្មភាពដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិតែប៉ុណ្ណោះទេ គឺមានចំពោះជីវភាពទាំងស្រុងរបស់អនីតិជនតែម្តង ដូច្នេះរាល់ការលូតលាស់ និងការការពារកូនដែលជាអនីតិជនដោយរួមទាំងការផ្តល់ចំណីអាហារ សម្លៀកបំពាក់ ការស្នាក់នៅ ការផ្តល់ការថែទាំវេជ្ជសាស្ត្រ ការឱ្យកូនចូលរៀន និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងកូនដែលជាអនីតិជន រួមទាំងការយកចិត្តទុកដាក់ចំពោះកូន និងផ្តល់ភាពកក់ក្តៅគឺដើម្បីឱ្យកូនមានទំនាក់ទំនងល្អ និងមានភាពជិតស្និតដែលធ្វើឱ្យកូនមានអារម្មណ៍ថាមិនឯកា និងទទួលបាននូវភាពកក់ក្តៅពីឪពុកម្តាយ ដូច្នេះឪពុកម្តាយ ឬអ្នកអាណាព្យាបាលដែលជាអ្នកមានអំណាចមេបាត្រូវប្រើប្រាស់អំណាចមេបាក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនដោយការរួមសហការគ្នា។[29] ជាក់ស្តែងការចិញ្ចឹមបីបាច់ថែរក្សាកូននៅក្នុងទិដ្ឋភាពច្បាប់ក៏បង្ហាញឱ្យឃើញផងដែរ មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យកូនក្លាយជាពលរដ្ឋល្អនៅក្នុងសង្គម។[30]

### កថាខណ្ឌទី២៖ ការអប់រំកូន

ការអប់រំកូន គឺជារឿងសំខាន់ព្រោះទង្វើរបស់ឪពុកម្តាយអាចជះឥទ្ធិពលទាំងល្អ និងអាក្រក់ដល់កូនៗបាន ហើយការអប់រំក៏មិនអាចចាប់បង្ខំបានទេអ្វីដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលគួរធ្វើគឺបណ្តុះទម្លាប់កូនឱ្យចូលចិត្តការសិក្សា និងមានក្រមសីលធម៌ក្នុងការរស់នៅល្អ និងធ្វើជាគម្រូល្អៗដល់កូន និងបង្រៀន

---

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៦ វាក្យខណ្ឌទី១។

[30] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៤៧ វាក្យខណ្ឌទី១។

កូនមិនឱ្យប្រព្រឹត្តអំពើដែលផ្ទុយនឹងច្បាប់។ បើយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចែងអំពីអ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចអប់រំកូន ពោលគឺជំរុញការអភិវឌ្ឍខាងបញ្ញារបស់កូន និងផ្តល់ឱ្យកូនទទួលបានចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ជីវិតនៅក្នុងសង្គមរបស់ខ្លួន។ ការអប់រំអាចបែងចែកជា២ គឺការអប់រំនៅក្នុងផ្ទះ និងការអប់រំនៅក្នុងសាលាដែលជាមូលដ្ឋានក្នុងការអប់រំផ្នែកបញ្ញា លើសពីនេះឪពុក ឬម្តាយមិនត្រូវបានអនុញ្ញាតឱ្យប្រើអំពើហិង្សាដោយហៅអំពើហិង្សានោះថាជា វិន័យ ការអប់រំ ឬផ្តល់នូវការអប់រំ ដែលមិនត្រឹមត្រូវសម្រាប់ការរីកលូតលាស់របស់កូនក្រោមរូបភាពនៃការប្រើប្រាស់សិទ្ធិនេះឡើយ ប៉ុន្តែនៅពេលផ្តល់ការអប់រំដល់កូនគាត់អាចស្តីបន្ទោស ឬដាក់ទណ្ឌកម្មកូននៅក្នុងកម្រិតមួយដែលចាំបាច់សម្រាប់ការអប់រំនៅក្នុងផ្ទះតែប៉ុណ្ណោះ តែត្រូវធានាថាការដាក់ទណ្ឌកម្មនោះមិនធ្វើឱ្យមានការរងគ្រោះផ្នែកផ្លូវចិត្ត ឬផ្លូវកាយដល់កូនជាដាច់ខាត។[31] ជាការពិតណាស់ការដាក់ទណ្ឌកម្មដល់កូនធ្វើឡើងក្នុងគោលបំណង ដើម្បីអប់រំកូន ហើយអ្នកមានអំណាចមេបាគួរតែមានសិទ្ធិក្នុងការដាក់ទណ្ឌកម្មកូនដោយខ្លួនឯង នៅពេលដែលកូនប្រព្រឹត្តអំពើប្រឆាំងនឹងសង្គម ឬអំពើដែលពុំគប្បី ប៉ុន្តែការដាក់ទណ្ឌកម្មនោះក្នុងទំហំដែលចាំបាច់សម្រាប់ការអប់រំដល់កូនតែប៉ុណ្ណោះ។ ដូចនេះការដាក់ទណ្ឌកម្មដែលបណ្តាលឱ្យមានការរងគ្រោះផ្នែកផ្លូវចិត្ត ឬ ផ្លូវកាយដល់កូនក្នុងនាមជាវិន័យមិនត្រូវបានអនុញ្ញាតឡើយ ហើយប្រសិនបើអ្នកមានអំណាចមេបាបានដាក់ទណ្ឌកម្មហួសពីកម្រិតនៃការចាំបាច់គេអាចប្រកាសព្យួរ ឬដកហូតអំណាចមេបានោះបានតាមផ្លូវតុលាការ។

ជាងនេះទៅទៀតអ្នកមានអំណាចមេបា ត្រូវមានករណីយកិច្ចឱ្យកូនចូលសាលាយ៉ាងតិចណាស់៩ឆ្នាំ។ មានន័យថាអ្នកមានអំណាចមេបា មិនត្រូវបានអនុញ្ញាតឱ្យហាមឃាត់កូនមិនឱ្យចូលរៀនដោយពុំមានហេតុផលពិសេសជាក់លាក់ឡើយ។ ក្រៅតែពីការផ្តល់ការអប់រំ អ្នកមានអំណាចមេបាត្រូវមានទីសំណាក់សម្រាប់កូនដែលមិនអាចកំណត់ទីតាំងសំណាក់របស់កូននៅទីកន្លែងដែលមិនសមរម្យនោះទេ មិនត្រឹមតែប៉ុណ្ណោះអ្នកមានអំណាចមេបាត្រូវអនុញ្ញាតឱ្យកូនប្រកបវិជ្ជាជីវៈ និងអាជីវកម្ម ថ្វីត្បិតតែច្បាប់បានកំណត់អំពីការប្រកបវិជ្ជាជីវៈ និងអាជីវកម្ម ត្រូវមានការអនុញ្ញាតពីអ្នកដែលមានអំណាចមេបាក្តី ក៏អ្នកដែលមានអំណាចមេបាត្រូវតែផ្តល់ការអនុញ្ញាតឱ្យកូនផងដែរ ដោយហេតុថាការដែលមិនអនុញ្ញាតឱ្យកូនក៏ចាត់ទុកជាការបំពានលើសិទ្ធិក្នុងការផ្តល់ការអនុញ្ញាត។[32]

## កថាខណ្ឌទី៣៖ ការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលរបស់កូន

អំពើអនីត្យានុកូល គឺជារបបនៃការទទួលខុសត្រូវរបស់អ្នកប្រព្រឹត្តអំពើបំពានណាមួយដែលត្រូវសងការខូចខាតដល់ជនរងគ្រោះដែលបង្កដោយសារអំពើនោះ។ អំពើអនីត្យានុកូល ឬអាចហៅម្យ៉ាងទៀតបានថាជា

[31] សៀវភៅអ្នកមានអំណាចមេបា, លោកស្រី នូ ច័ន្ទសុគន្ធា។

[32] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ ការដកហូត និងការព្យួរអំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០។

ប្រភេទមួយនៃព្រឹត្តិការណ៍គតិយុត្តដោយតាមរយៈនេះបុគ្គលជាចារីបានបំពានដល់សិទ្ធិ ឬផលប្រយោជន៍របស់អ្នកដទៃ។ ការបំពាននេះទោះក្រោមជាអំពើសកម្ម ឬអំពើអកម្មក្តី។ ការដែលនាំឲ្យមានការទទួលខុសត្រូវក្នុងអំពើអនីត្យានុកូលនេះដោយសារគោលការណ៍ទូទៅនៃការទទួលខុសត្រូវដោយមានកំហុស។

ជាការពិតណាស់ប្រសិនបើកូនបានបង្កឱ្យមានអំពើអនីត្យានុកូល អ្នកដែលមានករណីយកិច្ចត្រួតពិនិត្យគឺសំដៅទៅលើអ្នកជាឪពុកម្តាយ ឬម្តាយ ឬឪពុក ឬអាណាព្យាបាល បុគ្គលមានករណីយកិច្ចដែលច្បាប់បានកំណត់ក្នុងការត្រួតពិនិត្យ អនីតិជន ។ អនីតិជន គឺជាជនដែលមានសមត្ថភាពក្នុងការវិនិច្ឆ័យឆន្ទៈមិនគ្រប់គ្រាន់ ហេតុនេះនៅក្រោមគោលការណ៍នៃការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ប្រសិនបើអនីតិជនបានប្រព្រឹត្តអំពើអនីត្យានុកូល អនីតិជននោះមិនត្រូវទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលនោះទេ។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺជាការទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ក៏ប៉ុន្តែដោយសារអនីតិជនមិនទទួលខុសត្រូវផ្នែករដ្ឋប្បវេណី និងដើម្បីការពារជនរងគ្រោះ ដោយសារអំពើដែលអនីតិជនបានប្រព្រឹត្ត ដូច្នេះច្បាប់កំណត់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជំនួសអនីតិជន ដែលអ្នកទទួលខុសត្រូវនោះហៅថាអ្នកមានករណីយកិច្ចត្រួតពិនិត្យដែលនៅក្នុងករណីនេះ គឺអ្នកមានអំណាចមេបា។[33] ចំពោះអនីតិជនដែលមានអាយុក្រោម ១៤ឆ្នាំ ឬមានវិបត្តិខាងស្មារតី ឬមូលហេតុផ្សេងៗទៀត ត្រូវសងនូវការខូចខាតរបស់អ្នកដ៏ទៃដោយអំពើបំពានរបស់អ្នកនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះ ក៏ប៉ុន្តែបើកូនមានអាយុចាប់ពី ១៤ឆ្នាំ ឡើងទៅការទទួលខុសត្រូវរបស់អ្នកមានអំណាចមេបាត្រូវបន្ថយ មានន័យថា អនីតិជនត្រូវទទួលខុសត្រូវចំពោះការខូចខាតរបស់អ្នកដទៃផងដែរ ដោយសារអំពើរបស់ខ្លួនវាគឺជាការទទួលខុសត្រូវដោយសាមគ្គីភាពរវាងអ្នកមានអំណាចមេបា និងកូន។ ក្នុងករណីនេះលុះត្រាតែកូនមានទ្រព្យសម្បត្តិតាមរយៈប្រទានកម្ម ឬសន្តតិកម្ម ហេតុនេះអាចទទួលខុសត្រូវដោយសាមគ្គីជាមួយអ្នកមានអំណាចមេបា។ ប៉ុន្តែនៅក្នុងករណីកូនគ្មានទ្រព្យសម្បត្តិ កូនមិនអាចទទួលខុសត្រូវដោយសាមគ្គីជាមួយអ្នកមានអំណាចមេបាបានឡើយ ទោះបីជាកូនមានអាយុច្រើនជាង ១៤ឆ្នាំក៏ដោយ ហើយសម្រាប់ស្ថានភាពនេះដែរអ្នកមានអំណាចមេបានឹងទទួលខុសត្រូវចំពោះសំណងនៃការខូចខាតទាំងស្រុង។

## កថាខណ្ឌទី៤៖ ការគ្រប់គ្រងទ្រព្យសម្បត្តិកូន

អ្នកមានអំណាចមេបា មានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និងក្នុងការតំណាងឱ្យកូននោះចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ។[34] ប៉ុន្តែបើសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ សកម្មភាពរបស់អ្នកមានអំណាចមេបាបង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុជាសកម្មភាព

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា៧៤៦។
[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥៣។

របស់កូននោះ អ្នកមានអំណាចមេបាត្រូវទទួលការយល់ព្រមពីកូននោះ។ ជាធម្មតា អនីតិជនពុំមានទ្រព្យសម្បត្តិច្រើនទេ ប៉ុន្តែអនីតិជនទទួលបាននូវទ្រព្យសម្បត្តិតាមរយៈ សន្តតិកម្ម ប្រទានកម្ម សំណងនៃការខូចខាត ឬប្រាក់ដែលបានមកពីការធានារ៉ាប់រងជាអាទិ៍។ ម៉្យាងទៀតដោយសារកូនជាអនីតិជន ដែលពុំមានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាពថែរក្សាចាត់ចែងទ្រព្យសម្បត្តិដោយខ្លួនឯងបានឡើយ ទើបច្បាប់កំណត់ថាអ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ និងតំណាងឱ្យកូនទាក់ទងនឹងសកម្មភាពទាំងនោះ។ ជាការពិតណាស់អ្នកមានអំណាចមេបាអាចធ្វើសកម្មភាពគតិយុត្តដែលមិនត្រឹមតែសកម្មភាពគ្រប់គ្រងទ្រព្យសម្បត្តិតែប៉ុណ្ណោះទេ គឺថែមទាំងមានសកម្មភាពថែរក្សានិងសកម្មភាពចាត់ចែងទ្រព្យសម្បត្តិផងដែរ។[35]

លើសពីនេះ ទោះបីជាអ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនក៏ដោយបើទ្រព្យសម្បត្តិដែលអនីតិជនទទួលបានការអនុញ្ញាតឲ្យចាត់ចែង ឬប្រកបអាជីវកម្ម ឬតតិយជនបានផ្តល់ទ្រព្យសម្បត្តិទៅឲ្យកូនដោយបង្ហាញឆន្ទៈថាមិនឱ្យឪពុកម្តាយណាម្ខាង ឬទាំងសងខាងដែលអនុវត្តអំណាចមេបាគ្រប់គ្រងទ្រព្យសម្បត្តិទេ ទ្រព្យសម្បត្តិទាំងនោះពុំស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកមានអំណាចមេបាឡើយ។ ទោះបីជាមានតតិយជនបានបង្ហាញឆន្ទៈដូចខាងលើក៏ដោយ ក៏អនីតិជនមិនអាចគ្រប់គ្រងទ្រព្យសម្បត្តិនេះដោយខ្លួនឯងបានទេ ក្នុងករណីនេះតតិយជននោះអាចកំណត់អំពីអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបាន។ ប៉ុន្តែបើពុំបានកំណត់ទេ ទោះបីជាបានកំណត់ក៏ដោយកាលបើសិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងនោះត្រូវរលត់ ឬមានការចាំបាច់ផ្លាស់ប្តូរ ហើយតតិយជននោះមិនបានកំណត់អ្នកអនុវត្តគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់ ឬគ្រងទ្រព្យសម្បត្តិបានតាមការទាមទាររបស់កូន ឬញាតិក្នុង៤ថ្នាក់របស់កូន ឬតំណាងអយ្យការ។[36]

## កថាខណ្ឌទី៥៖ ការទាមទារឱ្យប្រគល់កូន

អ្នកមានអំណាចមេបាអាចទាមទារឱ្យតតិយជនដែលមិនព្រមប្រគល់កូន ដោយផ្ទុយនឹងច្បាប់ប្រគល់កូនបាន។[37] មានន័យថា បើកូននោះត្រូវតតិយជនយកទៅគ្រប់គ្រងតាមរយៈកិច្ចសន្យាយកទៅចិញ្ចឹម ឬយកទៅធ្វើអ្វីផ្សេងក្រៅពីនេះដែលខុសច្បាប់ អ្នកមានអំណាចមេបាអាចទាមទារឲ្យតតិយជននោះប្រគល់កូនមកឱ្យខ្លួនវិញបាន។ អ្នកមានអំណាចមេបាអាចទាមទារសំណងពីតតិយជនបានដោយសារការរំលោភលើអំណាចមេបាក៏ប៉ុន្តែបើអនីតិជនបង្ហាញឆន្ទៈថាចង់រស់នៅជាមួយតតិយជនដោយមិនមានការចាប់បង្ខំ តែព្រមដោយស្ម័គ្រចិត្ត

[35] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០, មាត្រា១០៥៣។

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥៨ កថាខណ្ឌទី២។

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៤៧ កថាខណ្ឌទី១។

មិនមានអ្វីដែលខុសច្បាប់ទេ។ ប៉ុន្តែបើតតិយជននោះកំពុងការពារកូននោះពីស្ថានភាពចាំបាច់អ្វីមួយគឺតតិយជននឹងរួចផុតពីការទទួលខុសត្រូវចំពោះមុខច្បាប់។

ដោយឡែក ករណីដែលឪពុកម្តាយបានលែងលះគ្នា ហើយឪពុក ឬម្តាយណាម្ខាងត្រូវបានកំណត់ជាអ្នកដែលមានអំណាចមេបា ប៉ុន្តែ ឪពុក ឬម្តាយម្ខាងទៀតមិនព្រមប្រគល់កូន ដូច្នេះអ្នកមានអំណាចមេបាអាចទាមទារឱ្យឪពុក ម្តាយ ដែលពុំមានអំណាចមេបាប្រគល់កូនបាន។ ប្រសិនបើអនីតិជនដែលមានសមត្ថភាពខាងឆន្ទៈបន្តរស់នៅជាមួយឪពុក ឬម្តាយ ដែលមិនមានអំណាចមេបាដោយឆន្ទៈរបស់ខ្លួនផ្ទាល់ ឆន្ទៈរបស់កូននោះមិនគួរត្រូវបានអើពើទាំងស្រុងទេ ហេតុដូច្នេះអ្នកដែលមានអំណាចមេបាត្រូវពិភាក្សាគ្នាដើម្បីដោះស្រាយបញ្ហានេះ។[38] ទោះបីជាការសម្រេចសិទ្ធិរបស់អ្នកដែលមានអំណាចមេបាជាការសំខាន់ក៏ដោយ ក៏គួរតែមានការដោះស្រាយបញ្ហាស្របទៅតាមកាលៈទេសៈដោយផ្តល់អាទិភាពដល់សុខុមាលភាពរបស់កូន។

## ផ្នែកទី២៖ សិទ្ធិ និងករណីយកិច្ចអ្នកពុំមានអំណាចមេបា

បុគ្គលដែរពុំមានអំណាចមេបា គឺសំដៅលើឪពុក ឬម្តាយដែលតុលាការមិនបានកំណត់ឱ្យក្លាយជាអ្នកមានអំណាចមេបា គឺកំណត់យកនរណាម្នាក់ដែលអាចជាភាគីណាម្នាក់នៃឪពុក ឬម្តាយ។ ឪពុក ឬម្តាយដែលទទួលបានសិទ្ធិគ្រប់គ្រងកូននៅតែមានចំណងញាតិស្របច្បាប់ជាមួយកូន ជាឪពុក ឬជាម្តាយដដែល។ ការប្រគល់សិទ្ធិឲ្យឪពុកជាអ្នកគ្រប់គ្រងកូន មិនមែនមានន័យថាចំណងគតិយុត្តរវាងកូន និងម្តាយ ត្រូវកាត់ផ្តាច់នោះទេ ហើយការប្រគល់សិទ្ធិទៅអោយម្តាយជាអ្នកគ្រប់គ្រងកូន ក៏មិនមែនមានន័យថាចំណងគតិយុត្តជាឪពុកត្រូវកាត់ផ្តាច់នោះដែរ។ ឪពុក ឬម្តាយដែលមិនបានទទួលសិទ្ធិគ្រប់គ្រងកូន នៅតែមានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទងជាមួយនឹងកូនហើយក្នុងពេលជាមួយគ្នានៅតែមាន ករណីយកិច្ចចូលរួមទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

ចំណែកឯឪពុក ឬម្តាយដែលទទួលសិទ្ធិគ្រប់គ្រងកូន ត្រូវបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ភាគីម្ខាងទៀតក្នុងការចូលជួបសួរសុខទុក្ខនិងប្រាស្រ័យទាក់ទងជាមួយកូន។ របៀបនៃការចូលជួបការប្រាស្រ័យទាក់ទងជាមួយកូន និងការចូលរួមចំណែកក្នុងសោហ៊ុយចាំបាច់ក្នុងការគ្រប់គ្រងថែរក្សា កូន(អាហារកិច្ច) គឺត្រូវកំណត់តាមរយៈការជជែកពិភាក្សាគ្នារវាង ឪពុក និងម្តាយ។ ប្រសិនបើឪពុក ម្តាយ មិនមានការព្រមព្រៀងគ្នាទេ គឺតុលាការជាអ្នកសម្រេចដោយយកផលប្រយោជន៍កូនជាធំ ហើយនៅក្នុងការកំណត់អំពីអាហារកិច្ចតុលាការក៏ត្រូវគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និងស្ថានភាពសេដ្ឋកិច្ចរបស់ឪពុក ម្តាយដែរ។ ចំណុចសំខាន់មួយទៀត ឪពុក ឬម្តាយដែលមិនទទួលបានសិទ្ធិគ្រប់គ្រងកូន នៅតែមានសិទ្ធិទាមទារឱ្យភាគីម្ខាងទៀតរាយការណ៍

[38] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។

អំពីស្ថានភាពរបស់កូននេះបាន។ ម្យ៉ាងទៀតចំពោះកិច្ចការសំខាន់ៗដែលទាក់ទងនឹងអាយុជីវិតកូន ទាក់ទងនឹងអនាគតកូន ឪពុក ឬម្ដាយដែលទទួលសិទ្ធិគ្រប់គ្រងកូនមានកាតព្វកិច្ចពិភាក្សាជាមួយនឹងភាគីម្ខាងទៀតមុននឹងធ្វើការសម្រេចអ្វីមួយលើកលែងតែក្នុងករណីចាំបាច់បន្ទាន់មិនអាចពិភាក្សាគ្នាបាន។

កិច្ចការចាំបាច់ដែលច្បាប់តម្រូវឱ្យមានការពិភាក្សាគ្នាគឺមាន ៖

- ការអប់រំកូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំ ដែលកំណត់ដោយច្បាប់ដូចជាការបញ្ជូនកូនឱ្យទៅរៀននៅមហាវិទ្យាល័យ ឬបញ្ជូនកូនឱ្យទៅរៀននៅបរទេសជាដើម។
- ការផ្លាស់ប្ដូរទីសំណាក់របស់កូន ពីខេត្តក្រុងមួយទៅខេត្តក្រុងមួយទៀត។ ការពិគ្រោះយោបល់គ្នាលើចំណុចនេះវាមានសារៈសំខាន់ ដើម្បីចៀសវាងកុំឱ្យប៉ះពាល់ទៅដល់សិទ្ធិក្នុងការជួបសួរសុខទុក្ខ និងការប្រាស្រ័យទាក់ទងជាមួយកូន។
- សេចក្ដីសម្រេចទាក់ទងនឹងវិជ្ជាជីវៈ ឬអាជីវកម្មរបស់កូន ដូចជាការសម្រេចឱ្យកូនឈប់រៀនហើយចាប់ផ្ដើមប្រកបការងារអ្វីមួយ ឬក៏ឱ្យកូនផ្អាក ឬបញ្ឈប់ការសិក្សាដើម្បីទៅបួសជាដើម។
- សកម្មភាពព្យាបាលដែលទាក់ទងដល់អាយុជីវិតរបស់កូន។
- ការចាត់ចែងទ្រព្យសម្បត្តិរបស់កូន។
- ការសម្រេចសំខាន់ៗផ្សេងទៀតដែលទាក់ទងនឹងការគ្រប់គ្រង ថែរក្សាកូន និងទ្រព្យសម្បត្តិរបស់កូន។ ការដែលច្បាប់ចែងត្រង់ចំណុចចុងក្រោយនេះ គឺដើម្បីទុកលទ្ធភាពឱ្យឪពុក ម្ដាយធ្វើការពិចារណាដោយខ្លួនឯងអំពីចំណុចសំខាន់ផ្សេងៗទៀតដែលមិនមានចែងនៅក្នុងប៉ុន្មានចំណុចខាងលើ ប៉ុន្តែជាចំណុចសំខាន់ដែលចាំបាច់ត្រូវធ្វើការពិភាក្សាគ្នាមុននឹងសម្រេចចិត្ត។[39]

### កថាខណ្ឌទី១៖ ការចូលជួប ឬប្រាស្រ័យទាក់ទងជាមួយកូន និងការទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់គ្រប់គ្រងថែរក្សាកូន

ឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនអាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ វាគឺជាសិទ្ធិ ហើយជាមួយគ្នាក៏ជាករណីយកិច្ចរបស់ឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនដែរ។ ម្យ៉ាងវិញទៀតកូនក៏មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនដែរ។ ទោះបីជាឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូន មិនមែនជាអ្នកដែលមានអំណាចមេបាក៏ដោយ ដរាបណាគាត់នៅតែជាឪពុក ឬម្ដាយ នោះឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនចាំបាច់ត្រូវចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនដើម្បីការលូតលាស់ដ៏ប្រសើររបស់កូន។

[39] ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ អំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០។

ផ្ទុយទៅវិញប្រសិនបើឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនធ្លាប់បានរំលោភបំពានទៅលើកូនពីអតីតកាល ឬប្រសិនបើការចូលជួប ឬប្រាស្រ័យទាក់ទងនឹងគ្នាមិនបណ្ដោយឱ្យមានផលប្រយោជន៍ដល់សុខុមាលភាពរបស់កូននោះទេ ឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូននោះអាចនឹងត្រូវហាមឃាត់មិនឱ្យទាក់ទងជាមួយនឹងកូន។ ជាការពិតណាស់សុខុមាលភាពរបស់កូនមានអាទិភាពជាងបញ្ហាផ្សេងៗទាំងអស់ ប្រសិនលើការចូលជួប ឬការប្រាស្រ័យទាក់ទងគ្នាជាមួយឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនអាចជួយដល់ការរីកលូតលាស់របស់កូន ការចូលជួប ឬការប្រាស្រ័យទាក់ទងគ្នានេះគួរតែត្រូវបានអនុញ្ញាត រីឯប្រសិនបើធ្វើឱ្យមានការរាំងស្ទះ ឬអាចនឹងបណ្ដាលឱ្យមានការរាំងស្ទះដល់ការរីកលូតលាស់របស់កូន ការចូលជួបនិងការប្រាស្រ័យទាក់ទងគ្នានេះមិនគួរត្រូវបានអនុញ្ញាតឡើយ។ ម្យ៉ាងទៀតការចូលជួប និងប្រាស្រ័យទាក់ទងគ្នានេះ មិនគួរត្រូវបានផ្សារភ្ជាប់ជាមួយនឹងការបែងចែកបន្ទុកនៃសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគ្មានការគិតគូរហ្មត់ចត់ឡើយ។ មានន័យថាទោះបីជាឪពុក ឬម្ដាយដែលមិនរស់នៅជាមួយពុំបានទទួលបន្ទុកនូវចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូនក៏ដោយ ក៏រឿងនោះមិនត្រូវយកមកធ្វើជាមូលហេតុក្នុងការហាមឃាត់ឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូននោះមិនឱ្យចូលជួប ឬប្រាស្រ័យទាក់ទងជាមួយកូន ឬក្នុងការតម្រូវឱ្យឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូននោះបង់ប្រាក់ចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ដើម្បីជាថ្នូរនឹងការយល់ព្រមឱ្យចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូននោះដែរ។ ការចូលជួប និងការប្រាស្រ័យទាក់ទងនេះមិនត្រូវយកមកប្រើជាមធ្យោបាយក្នុងការចរចាឡើយ។[40]

### កថាខណ្ឌទី២៖ ការទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

ឪពុក ឬម្ដាយដែលពុំមានអំណាចមេបាក៏នៅតែជាឪពុក ឬម្ដាយតាមច្បាប់របស់កូនដែរ។ ម្យ៉ាងទៀតឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនអាចមានករណីយកិច្ចច្រើនក្នុងនាមជាឪពុកឬម្ដាយដូចជាករណីយកិច្ចក្នុងការបង់ការចំណាយលើការចិញ្ចឹមកូនជាដើម។ ដូច្នេះការដឹងពីស្ថានភាពកូនដែលមិនរស់នៅជាមួយខ្លួន គឺជាករណីយកិច្ចរបស់ឪពុក ឬម្ដាយនោះដើម្បីធានាឱ្យមានការរីកលូតលាស់បានយ៉ាងល្អរបស់កូន។ ហេតុផលគឺដោយសារថាការដឹងអំពីស្ថានភាពរបស់កូន គឺជាការដឹងថាតើអ្នកដែលមានអំណាចមេបាទោលបានអនុវត្តអំណាចនេះបានត្រឹមត្រូវដែរឬទេ។[41]

## ផ្នែកទី៣៖ អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ច គឺជាកិច្ចដែលត្រូវតែបំពេញតាមច្បាប់ ឬតាមសេចក្ដីសម្រេចរបស់តុលាការដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្ដល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់

[40] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០, មាត្រា១០៤០។

[41] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០, មាត្រា១០៤១។

ទំនងញាតិនឹងគ្នា។[42] អាហារកាតព្វកិច្ច គឺមានបីប្រភេទដូចជាអាហារកាតព្វកិច្ចរវាងសហព័ទ្ធ អាហារកាតព្វកិច្ចរវាងញាតិ និងអាហារកាតព្វកិច្ចរវាងឪពុកម្ដាយ និងកូនជាអនីតិជន។ ប៉ុន្តែនៅក្នុងប្រធានបទនេះនឹងលើកឡើងតែអំពីអាហារកាតព្វកិច្ចរវាងឪពុកម្ដាយ និងកូនជាអនីតិជនតែប៉ុណ្ណោះ។

## កថាខណ្ឌទី១៖ ការផ្ដត់ផ្គង់អាហារកាតព្វកិច្ច

អាហារកាតព្វកិច្ចរវាងឪពុកម្ដាយចំពោះកូនជាអនីតិជន គឺជាអាហារកាតព្វកិច្ចមួយក្នុងចំណោមអាហារកាតព្វកិច្ចទាំងបីដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ហើយវានឹងកើតឡើងនៅក្រោយពេលរំលាយអាពាហ៍ពិពាហ៍តាមការព្រមព្រៀងរវាងភាគី ឪពុក ម្ដាយរបស់អនីតិជន ឬតាមសេចក្ដីសម្រេចរបស់តុលាការ។នៅពេលដែលសាលក្រមលែងលះចូលជាស្ថាពរ ចំណងអាពាហ៍ពិពាហ៍របស់ភាគីនោះត្រូវបានរំលាយ ហើយចំណងគតិយុត្តរវាងភាគីទាំងពីរដែលធ្លាប់មានរវាងគ្នានឹងគ្នាដូចពេលមានចំណងអាពាហ៍ពិពាហ៍របស់ភាគីនោះត្រូវបានរំលាយចំណងគតិយុត្តរវាងភាគីទាំងពីរដែលមានរវាងគ្នានឹងគ្នា ដូចពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។

ដូច្នេះការផ្ដត់ផ្គង់អាហារកាតព្វកិច្ច គឺជាកត្តាមួយដែលផ្ដល់លទ្ធភាពក្នុងការផ្សារភ្ជាប់នូវទំនាក់ទំនងញាតិ និងមនោសញ្ចេតនារវាងឪពុកម្ដាយ និងកូន ក្រោយពេលគ្រួសារបាក់បែកគ្នា។ បើយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្ដាយដែលមិនរស់នៅជាមួយកូនក្រោយពេលលែងលះត្រូវមានករណីយកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ហើយករណីយកិច្ចនេះសម្រាប់ភាគីម្ខាងទៀត ដែលគ្មានអំណាចមេបាក្រោយការលែងលះ។

### ១. បុគ្គលផ្ដត់ផ្គង់អាហារកាតព្វកិច្ច

បុគ្គលដែលមានកាតព្វកិច្ចត្រូវផ្ដត់ផ្គង់អាហារកាតព្វកិច្ចចំពោះកូនជាអនីតិជនរបស់ខ្លួន គឺត្រូវស្របនឹងការរស់នៅនូវក្នុងកម្រិតដូចគ្នានឹងជីវភាព និងឋានៈក្នុងសង្គមរបស់ខ្លួន និងរក្សាកម្រិតនៃការរស់នៅរបស់ខ្លួនឱ្យសមរម្យទៅតាមលទ្ធភាពទ្រព្យធន។ តុលាការមិនគួរចេញសេចក្ដីសម្រេចដែលបង្គាប់ឱ្យជនដែលមានករណីយកិច្ចត្រូវផ្ដត់ផ្គង់អាហារកាតព្វកិច្ចណាដែលធ្វើឱ្យមានការពិបាកដល់ជីវភាពរបស់ជនដែលមានករណីយកិច្ចត្រូវផ្ដត់ផ្គង់អាហារកាតព្វកិច្ចឡើយ។ មានន័យថា បើបុគ្គលដែលត្រូវផ្ដត់ផ្គង់អាហារកាតព្វកិច្ចមានជីវភាពខ្វះខាត ខ្វះនូវទ្រព្យធនដើម្បីផ្ដល់ទៅឱ្យកូន គឺតុលាការគួរពិចារណាទៅទំហំនៃលទ្ធភាពរបស់បុគ្គលផ្ដត់ផ្គង់អាហារកាតព្វកិច្ច។ របៀបផ្ដត់ផ្គង់អាហារកាតព្វកិច្ច ជាគោលការណ៍គឺជាការផ្ដល់តាវកាលិកនូវប្រាក់ពីជនដែលមានករណីយកិច្ចត្រូវផ្ដល់ផ្ដត់ផ្គង់អាហារកាតព្វកិច្ចទៅជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចនោះ។ ជាការពិតណាស់ប្រសិនបើអាច

[42] សន្ធានុក្រមច្បាប់នៃក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧,លេខរៀងទី២០២។

ដោះស្រាយភាពចាំបាច់នៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចតាមការផ្តល់តាវកាលិកនូវវត្ថុពីប្រាក់ ការផ្តល់តាវកាលិកនូវវត្ថុនោះក៏អាចធ្វើទៅបានបន្ទាប់ពីការពិភាក្សារវាងភាគី ឬតាមការសម្រេចរបស់តុលាការ។[43]

ម្យ៉ាងទៀតប្រសិនជាជនមានសិទ្ធិទទួលអាហារកិច្ចមានច្រើននាក់ ហើយលទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចពុំគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់ចំពោះជនទាំងនោះទេ នោះពួកគេត្រូវការធ្វើការពិភាក្សា ដើម្បីកំណត់អំពីចំណែកដែលត្រូវទទួលពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឱ្យបានជាក់លាក់។[44] ប៉ុន្តែបើការពិភាក្សានោះពុំបានសម្រេចទេ តុលាការត្រូវកំណត់អំពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចឱ្យបានជាក់លាក់ដោយគិតពិចារណាទៅលើលទ្ធភាពទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយចិត្តរបស់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ទំនាក់ទំនងបុគ្គលដែលជាភាគី និងស្ថានភាពផ្សេងទៀតទាំងអស់។[45]

### ២. បុគ្គលដែលទទួលបានអាហារកិច្ច(កូន)

ជាធម្មតា ដើម្បីអាចទទួលបាននូវអាហារកិច្ច គឺទាមទារឱ្យមានការព្រមព្រៀងដោយបង្ហាញឆន្ទៈរវាងជនដែលមានសិទ្ធិទទួលបានអាហារកិច្ច និងជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។ បុគ្គលដែលត្រូវការអាហារកិច្ច គឺជាជនដែលមិនអាចទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួនបានសូម្បីតែក្នុងកម្រិតទាបបំផុតដែលក្នុងពាក្យច្បាប់ត្រូវបានហៅថា ជនដែលមានសិទ្ធិទទួលបានអាហារកិច្ច។ ឧទាហរណ៍៖ កូនជាអនីតិជនពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរកចំណូលដើម្បីចិញ្ចឹមខ្លួនឯងដូចនេះកូននោះគឺត្រូវការជំនួយដើម្បីទ្រទ្រង់ជីវិត។

ក្នុងករណីនេះជនដែលមានសិទ្ធិទទួលបាននូវអាហារកិច្ច គឺជាកូនដែលជាអនីតិជនដែលមិនមានសមត្ថភាពធ្វើសកម្មភាព និងការត្រិះរិះពិចារណាមិនគ្រប់គ្រាន់នៅឡើយ។ ការបង់អាហារកាតព្វកិច្ចចំពោះកូនអាចត្រូវបានធ្វើឡើងតាមរយៈការព្រមព្រៀង ឬតាមការសម្រេចពីតុលាការ ច្បាប់ពុំបានដាក់កំហិតលើការកំណត់ពីទំហំអាហារកាតព្វកិច្ចដែលតម្រូវឱ្យបុគ្គលដែលជាប់កាតព្វកិច្ចបង់ក្នុងទំហំប៉ុណ្ណានោះឡើយ។ មួយវិញទៀតច្បាប់ក៏ពុំបានចែង ឬបញ្ញត្តិត្រង់ឃ្លា ឬមាត្រាណាមួយអំពីការបង់ផ្តាច់តែម្តងដើម្បីបញ្ចប់កាតព្វកិច្ចដូចគ្នា ពីព្រោះថាការបង់ផ្តាច់បែបនេះធ្វើឱ្យមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូនដែលជាអនីតិជន ក្នុងនាមជាអ្នកមានសិទ្ធិ។ ក្នុងករណីថាបើសិនជាច្បាប់បានចែង ឬបញ្ញតិអំពីការបង់ផ្តាច់វនឹងធ្វើឱ្យមានផលវិបាកដល់កូននៅក្នុងអំឡុងពេលជាអនីតិជននៅឡើយ បញ្ហានេះធ្វើឱ្យក្មេងបាត់បង់ប្រយោជន៍ជាច្រើនសម្រាប់ជីវភាពរស់នៅរបស់

---

[43] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០, មាត្រា១១៤២។
[44] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១១៤១ កថាខណ្ឌទី១។
[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១១៤១ កថាខណ្ឌទី២។

ពួកគេ ពួកគេប្រៀបដូចជាក្មេងកំព្រា គ្មានឪពុកទាំងម្ដាយ គ្មានអ្នកប្រៀបប្រដៅណែនាំ និងផ្ដល់ក្ដីស្រឡាញ់ដូចក្មេងឯទៀត។

## ៣. ការកំណត់សោហ៊ុយចំណាយ ចំពោះការផ្គត់ផ្គង់កូនជាអនីតិជន

ការកំណត់សោហ៊ុយចំណាយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ចំពោះទំហំនៃសោហ៊ុយចំណាយនោះមុនពេលចេញសាលក្រមតុលាការបានពិចារណាទៅលើចំណុចជាច្រើនដូចជា កម្រិតជីវភាពរបស់អ្នកគ្មានអំណាចមេបាដែលជាអ្នកផ្គត់ផ្គង់អាហារកាតព្វកិច្ច ថាតើបុគ្គលនោះមានសមត្ថភាពប៉ុនណាដើម្បីផ្ដល់សោហ៊ុយឱ្យកូនជាមធ្យមកម្រិតជីវភាពរបស់កូនដែលធ្លាប់មានកន្លងមកតម្រូវការចាំបាច់របស់កូនដូចជាតម្រូវការផ្នែកអប់រំ ឬម្ហូបអាហារជាដើម។បើក្រឡេកមើលទៅការកំណត់ទំហំសោហ៊ុយចំណាយចាំបាច់ដើម្បីថែរក្សាកូននៅក្នុងក្រមរដ្ឋប្បវេណី គឺមិនបានកំណត់អំពីរបៀបគណនាអំពីសោហ៊ុយចំណាយថាតើគួរចំណាយក្នុងកម្រិតណាមួយដើម្បីឱ្យសមស្របនឹងការចំណាយជាក់ស្ដែង ប៉ុន្តែក្នុងក្រមនោះក៏បានកំណត់សោហ៊ុយចាំបាច់ខ្លះៗដែរ។ ឪពុកម្ដាយដែលលែងលះគ្នា គឺមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងកូន។ ហេតុនេះហើយទើបបញ្ហាផ្សេងទៀតត្រូវបានកែប្រែ និងត្រូវផ្លាស់ប្ដូរនោះគឺវាទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិ ការបែងចែកអំណាចមេបាទៅលើកូន ជាពិសេសគឺទាក់ទងនឹងសោហ៊ុយចំណាយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន។

ការមិនអនុវត្តកាតព្វកិច្ចតាមសេចក្ដីសម្រេចរបស់តុលាការ ក្នុងចំណុចនេះសំដៅទៅលើបុគ្គលគ្មានអំណាចមេបាដែលមានករណីយកិច្ចផ្គត់ផ្គង់សោហ៊ុយចំណាយចាំបាច់ដល់កូនជាអនីតិជន ហើយមិនបានបង់សោហ៊ុយនោះតាមពេលកំណត់ ឬពុំបានបង់សោហ៊ុយនោះតែម្ដង។ដូចនេះចំពោះជនដែលមានករណីយកិច្ចផ្គត់ផ្គង់សោហ៊ុយចំណាយចាំបាច់ត្រូវទទួលទណ្ឌកម្មដូចជាការអនុវត្តដោយបង្ខំ។ ការអនុវត្តដោយបង្ខំជានីតិវិធីតាមផ្លូវតុលាការក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជនដោយប្រើអំណាចរដ្ឋ។ នីតិវិធីការអនុវត្តដោយបង្ខំនេះមានគោលបំណងការពារផលប្រយោជន៍របស់ម្ចាស់សិទ្ធិនៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី ដែលមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជនចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំ។ ក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចផ្ដល់តាវកាលិក ឬកូនបំណុលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ចដែលជាកម្មវត្ថុនៃការទាមទារ ឬសិទ្ធិប្រាតិភោគតាមរយៈការប្រើប្រាស់អំណាចអាជ្ញាធររបស់រដ្ឋ។ភាគីដែលជាអ្នកមានអំណាចមេបា ឬកូនដែលជាអនីតិជនដែលជាបុគ្គល មានសិទ្ធិទាមទារតាវកាលិកពីភាគីដែលមានកាតព្វកិច្ចផ្គត់ផ្គង់សោហ៊ុយចំណាយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាភាគីនោះអាចទាមទារឱ្យសម្រេចសិទ្ធិដោយការអនុវត្តដោយបង្ខំ។

ក្នុងករណីយឪពុកម្តាយបោះបង់គ្រួសារ ដោយមិនគោរពតាមសេចក្តីសម្រេចស្ថាពររបស់តុលាការដោយមិនព្រមបង់ពីរខែយ៉ាងតិចនូវអាហារកាតព្វកិច្ចដល់កូនជាអនីតិជន គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១(មួយ)សែន ដល់ ២(ពីរ)លានរៀល។[46]

## កថាខណ្ឌទី២៖ ការផ្លាស់ប្តូរ ឬការលុបចោលនៃអាហារកាតព្វកិច្ច

ការផ្លាស់ប្តូរ ឬការលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ចគឺធ្វើឡើងដោយផ្អែកទៅស្ថានភាពជាក់ស្តែងរបស់អ្នកផ្គត់ផ្គង់អាហារកាតព្វកិច្ច ថាតើគាត់មានបុគ្គលិកលក្ខណៈយ៉ាងដូចម្តេច? មានជីវភាពធូរធារ ឬអត់? គាត់មានសមត្ថភាពគ្រប់គ្រាន់សម្រាប់ផ្តល់អាហារកាតព្វកិច្ចទៅអ្នកមានសិទ្ធិទទួលបានអាហារកិច្ចដែរ ឬទេ? តើគាត់បានប្រព្រឹត្ត ឬបានធ្វើអ្វីដែលច្បាប់ហាមឃាត់ដែរ ឬទេ? ការផ្លាស់ប្តូរ ឬការលុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ចធ្វើតាមរយៈការពិភាក្សា ឬតាមរយៈសេចក្តីសម្រេចរបស់តុលាការ។

ប្រសិនបើមានការផ្លាស់ប្តូរស្ថានភាពក្រោយពីបានពិភាក្សា ឬក្រោយពីមានការសម្រេចសេចក្តីចំពោះជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ឬជនដែលទទួលអាហារកិច្ចជាក់លាក់ ឬកម្រិត ឬរបៀបនៃការឬផ្លាស់ប្តូរផ្គត់ផ្គង់អាហារកាតព្វកិច្ចភាគីអាចផ្លាស់ប្តូរបាន មានន័យថាទំនាក់ទំនងនៃអាហារកាតព្វកិច្ចអាចត្រូវបានលុបអាស្រ័យទៅតាមស្ថានភាពនៃការពិភាក្សា និងប្រសិនបើការពិភាក្សាមិនទទួលបានជោគជ័យតុលាការនឹងបង្គាប់ឱ្យលុបចោល ឬផ្លាស់ប្តូរសេចក្តីសម្រេចមុន។[47]

សិទ្ធិរបស់ជនដែលមានសិទ្ធិទទួលអាហារកិច្ចពីជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច គឺជាកម្មសិទ្ធដែលផ្តាច់មុខរបស់ជនដែលមានសិទ្ធិទទួលអាហារកិច្ច ហើយមិនអាចក្លាយទៅជាកម្មវត្ថុនៃការជួញដូរណាមួយឡើយអាស្រ័យហេតុនេះ ជនដែលមានសិទ្ធិទទួលអាហារកិច្ចនោះមិនត្រូវយកផលដែលទទួលបានពីជនផ្គត់ផ្គង់អាហារកាតព្វកិច្ចដើម្បីខ្ចីប្រាក់ពីអ្នករកស៊ី ចងការប្រាក់ ដូចសិទ្ធិលើបំណុលដែលនោះបានទេហើយមិនគួរឱ្យមានហេតុការណ៍នេះ។[48]

[46] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២ ធ្នូ ២០០៩, មាត្រា៣២៥។

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១១៤៣។

[48] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០, មាត្រា១១៤៤។

# ជំពូកទី៣
# ការផ្លាស់ប្តូរអ្នកមាន
# អំណាចមេឃ

# ជំពូកទី៣
# ការផ្លាស់ប្តូរអ្នកមានអំណាចមេបា

បើទោះបីជាអំណាចមេបាត្រូវបានកំណត់តាមការសម្រេចនៅពេលមានការលែងលះ តាមទំនាក់ទំនងរវាងការទទួលស្គាល់ក៏ដោយ ក៏តុលាការអាចផ្លាស់ប្តូរអ្នកមានអំណាចមេបាបានតាមការទាមទាររបស់ញាតិក្នុង៤(បួន)ថ្នាក់របស់កូន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន។[49] ការផ្លាស់ប្តូរអ្នកមានអំណាចមេបាគឺជាយន្តការតាមផ្លូវតុលាការមួយ ដើម្បីសង្គ្រោះកូនក្នុងករណីដែលអ្នកមានអំណាចមេបាមិនអាចអនុវត្តអំណាចមេបាបានកាលបើមានមូលហេតុមិនអាចជៀសវាងបាន។

## ផ្នែកទី១៖ ការបំពានករណីយកិច្ចជាអ្នកមានអំណាចមេបា

ក្នុងការអនុវត្តអំណាចមេបា អ្នកមានអំណាចមេបាត្រូវមានករណីយកិច្ច ក្នុងការគ្រប់គ្រងកូនដែលជាអនីតិជនឱ្យបានត្រឹមត្រូវដោយការប្រុងប្រយ័ត្ន និងមិនមានការបំពានសិទ្ធិជាអ្នកមានអំណាចមេបាជាដើម ប៉ុន្តែប្រសិនបើអ្នកមានអំណាចមេបាធ្វើការគ្រប់គ្រងដោយមានការធ្វេសប្រហែស ឬដោយមានការបំពានសិទ្ធិជាអ្នកមានអំណាចមេបានាំឱ្យមានការព្យួរ ឬដកហូតនូវអំណាចមេបានោះ។ចំពោះករណីមានការព្យួរ ឬដកហូត និងការលាឈប់ អានុភាពរបស់វាត្រូវបានកើតមានឡើងនៅពេលមានសេចក្តីសម្រេចរបស់តុលាការ មានន័យថាអំណាចមេបាដែលធ្លាប់មាននឹងត្រូវបាត់បង់ ក្នុងអំឡុងដែលបានកំណត់តាមរយៈខ្លឹមសារនៃសេចក្តីសម្រេច។ ចំពោះករណីអំណាចមេបាត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ គឺជាការមកដល់នីតិភាពរបស់កូន តុលាការអាចផ្លាស់ប្តូរអ្នកមានអំណាចមេបាបានតាមការទាមទាររបស់ញាតិក្នុង៤(បួន)ថ្នាក់ របស់កូនប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន។[50]

### កថាខណ្ឌទី១៖ ការព្យួរ ឬការដកហូតអំណាចមេបា

ការដកហូត ឬការប្រកាសព្យួរអំណាចមេបា គឺជាការដកសិទ្ធិទាំងស្រុង ឬបណ្តោះអាសន្នក្នុងការគ្រប់គ្រងកូនដែលជាអនីតិជនទៅតាមការស្នើសុំរបស់អ្នកដែលមានសិទ្ធិក្នុងការស្នើសុំ ប្រសិនបើអ្នកដែលមានអំណាចមេបាមិនបានបំពេញកាតព្វកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា។ ហេតុដូចនេះហើយទើបច្បាប់បានកំណត់ថាឪពុក ឬម្តាយដែលអនុវត្តអំណាចមេបាបានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសព្យួរ ឬដកហូតអំណាចមេបាតាមការទាមទាររបស់ញាតិក្នុង ៤ថ្នាក់របស់កូន មេឃុំ ចៅសង្កាត់ តំណាងអយ្យការ ឬនាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារបាន។ ក្នុងករណីដែលអ្នកមានអំណាចមេបាបានបំពាននូវ

---

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៩។

[50] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៣៩។

សិទ្ធិអំណាច ឬធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានសិទ្ធិអំណាចមេបាដូចជាការប្រើប្រាស់អំពើហិង្សាលើកូន ដោយការដាក់ទណ្ឌកម្មហួសពីកម្រិតនៃការចាំបាច់ដែលបណ្តាលឲ្យមានការរងគ្រោះផ្នែកផ្លូវចិត្ត ឬផ្លូវកាយដល់កូនក្នុងនាមជាវិន័យបណ្តាលឱ្យទទួលរងនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់កូនជាដើម តុលាការអាចប្រកាសព្យួរ ឬដកហូតអំណាចមេបា។

ជាក់ស្តែងក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបាបានប្រព្រឹត្តនូវអំពើហិង្សាទៅលើកូន ដែលហិង្សានេះកើតមានដោយសារការញៀនគ្រឿងស្រវឹង ឬប្រើប្រាស់នូវសារធាតុញៀន ដូច្នេះអំណាចមេបាត្រូវបានព្យួរ ឬដកហូត។ ជាការពិតណាស់ប្រសិនបើមានការប្រកាសព្យួរ ឬការដកហូតអំណាចមេបា ហើយធ្វើឲ្យកូនដែលជាអនីតិជនធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬម្តាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន ក្នុងករណីនេះដែរប្រសិនបើអ្នកដែលមានអំណាចមេបារៀបអាពាហ៍ពិពាហ៍ថ្មី ឬទទួលមរណភាព ដូច្នេះចំណុចខាងលើក៏ត្រូវបានយកមកអនុវត្តផងដែរ។[51]

## កថាខណ្ឌទី២៖ ការលុបចោលការប្រកាសព្យួរ និងការដកហូតអំណាចមេបា

ជាទូទៅប្រសិនបើការព្យួរ ឬការដកហូតអំណាចមេបាបានបញ្ចប់ហើយតុលាការអាចលុបចោលការប្រកាសព្យួរ ឬការដកហូតសិទ្ធិអំណាចក្នុងនាមអ្នកមានអំណាចមេបាតាមការទាមទាររបស់សាមីជនដែលបានទទួលការព្យួរ ឬការដកហូតអំណាចមេបានោះ ឬញាតិក្នុងបួនថ្នាក់របស់ជននោះបាន។[52] ជាក់ស្តែងក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបាបានប្រព្រឹត្តនូវអំពើហិង្សាទៅលើកូន ប៉ុន្តែពេលក្រោយមកបុគ្គលនោះបានជំនះដោយការឈប់ប្រើប្រាស់នូវអំពើហិង្សាមានការសោកស្តាយនូវអ្វីដែលខ្លួនបានប្រព្រឹត្តកន្លងមក និងចាប់ផ្តើមចង់បានមកវិញនូវអំណាចមេបា ដូច្នេះបុគ្គលនោះអាចទទួលបាននូវសិទ្ធិអំណាចមេបាវិញតាមរយៈការដាក់ពាក្យសុំទៅតុលាការឱ្យលុបចោលការព្យួរ ឬការដកហូតអំណាចមេបានោះ។ នៅក្នុងករណីនេះតុលាការគួរពិចារណាថាតើបុគ្គលនោះគួរទទួលបានមកវិញនូវអំណាចមេបាដោយការវិនិច្ឆ័យជាចម្បង ទៅលើការសម្រេចអោយបាននូវសុខមាលភាពរបស់កូន។[53]

## កថាខណ្ឌទី៣៖ ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា

ជាធម្មតាឪពុកម្តាយត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ក៏ប៉ុន្តែប្រសិនបើមានឪពុក ឬម្តាយណាម្នាងពុំអាចប្រើប្រាស់អំណាចមេបាបានទេ ដូចជាករណីឪពុក ឬម្តាយបាត់បង់សតិជាអាទិ៍ ឪពុក ឬម្តាយម្ខាងទៀតត្រូវប្រើប្រាស់អំណាចមេបានោះ។[54] ប៉ុន្តែក្នុងករណីមានតែឪពុក ឬម្តាយដែលជាអ្នកមានអំណាចមេបា

---

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥១ កថាខណ្ឌទី១។

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៤៩។

[53] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០, មាត្រា១០៤៩។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៦៣ វាក្យខណ្ឌទី២។

ហើយកូនបានធ្លាក់ក្នុងស្ថានភាពជាកូនដែលពុំមានអ្នកមានអំណាចមេបាដោយសារការប្រកាសព្យួរ ឬដកហូតអំណាចមេបា ឬការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬម្តាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន។[55]

ជាទូទៅការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា គឺជាយន្តការមួយដែលតាមរយៈនោះតុលាការអនុញ្ញាតឲ្យអ្នកមានអំណាចមេបាទោល (ឪពុក ឬ ម្តាយ) លាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ឬអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនបាន។ ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាត្រូវធ្វើឡើងតាមរយៈពាក្យសុំរបស់អ្នកមានអំណាចមេបានោះ។ តុលាការដែលមានសមត្ថកិច្ច គឺតុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា។ ការសម្រេចសេចក្តីអំពីពាក្យសុំការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាធ្វើឡើងតាមរយៈដីកាសម្រេច។ ប្រសិនបើអ្នកដែលមានអំណាចមេបាទោលមិនអាចអនុវត្តនូវអំណាចមេបាបានដោយសារកាលៈទេសៈដែលមិនអាចជៀសវាងបានដូចជាត្រូវជាប់ពន្ធនាគារ ការសម្រាកនៅមន្ទីរពេទ្យរយៈពេលវែង ការធ្វើដំណើរទៅបរទេស តុលាការអាចអនុញ្ញាតឲ្យមានការលាឈប់ពីការធ្វើជាអ្នកដែលមានអំណាចមេបាតាមពាក្យសុំរបស់អ្នកដែលមានអំណាចមេបា។

ក្នុងករណីដែលតុលាការអនុញ្ញាតឱ្យមានការលាឈប់នេះ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវតែងតាំងសម្រាប់អនីតិជន។[56] ឧទាហរណ៍៖ ប្រសិនបើឪពុក ឬម្តាយដែលអនុវត្តអំណាចមេបាបានប្រព្រឹត្តបទល្មើសជួញដូរ និងប្រើប្រាស់នូវសារធាតុញៀន ដែលត្រូវជាប់ពន្ធនាគារនោះតុលាការអាចអនុញ្ញាតឲ្យលាឈប់បានព្រមនឹងគ្នានោះដែរប្រសិនបើឪពុក ឬម្តាយមានបញ្ហាសុខភាពដែលតម្រូវសម្រាកក្នុងមន្ទីរពេទ្យរយៈពេលយូរនោះតុលាការអាចអនុញ្ញាតឲ្យលាឈប់បានដូចគ្នាផងដែរ។ ហើយបើមូលហេតុណាមួយនោះត្រូវបានបញ្ចប់ហើយឪពុក ឬម្តាយដែលបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាទទួលបដិទាននូវអំណាចមេបានោះវិញបានដោយទទួលការអនុញ្ញាតពីតុលាការ។[57] ប្រសិនឪពុក ឬម្តាយជាអ្នកមានអំណាចមេបាត្រូវបានជាប់ពន្ធនាគារ ឬសម្រាកក្នុងមន្ទីរពេទ្យរយៈពេលយូរដែលធ្វើឱ្យកូនពុំមានអ្នកមានអំណាចមេបានាំឱ្យឪពុក ឬម្តាយដែលពុំបានធ្វើជាអ្នកមានអំណាចមេបាត្រូវក្លាយជាអ្នកអំណាចមេបាដោយស្វ័យប្រវត្តិ ក៏ប៉ុន្តែប្រសិនបើឪពុក ឬម្តាយដែលត្រូវក្លាយជាអ្នកមានអំណាចមេបានោះបានទទួលមរណៈភាព ក្នុងអំឡុងពេលអនុវត្តអំណាចមេបានោះតុលានឹងត្រូវធ្វើការជ្រើសរើសអ្នកតំណាងពិសេសឲ្យកូនដោយឆន្ទានុសិទ្ធិ។

[55] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥១ កថាខណ្ឌទី១។

[56] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥២ កថាខណ្ឌទី១។

[57] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៤០ កថាខណ្ឌទី២។

## កថាខណ្ឌទី៤៖ អ្នកមានអំណាចមេបាទទួលមរណៈភាព

ប្រសិនបើឪពុកម្តាយ បានកំណត់អ្នកដែលមានអំណាចមេបាតាមការពិភាក្សានៅពេលលែងលះហើយ អ្នកដែលមានអំណាចមេបាទោលនោះទទួលមរណភាព កូននឹងមិនត្រូវដាក់ឲ្យស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជនឡើយ ក៏ប៉ុន្តែ ឪពុក ឬ ម្តាយដែលនៅរស់នឹងក្លាយជាអ្នកដែលមានអំណាចមេបា។ មានន័យថាឪពុក ម្តាយដែលនៅរស់នោះត្រូវក្លាយជាអ្នកមានអំណាចមេបាដោយស្វ័យប្រវត្តិតាមបញ្ញត្តិច្បាប់។[58] ផ្ទុយទៅវិញ ក្នុងករណីដែលឪពុកម្តាយដែលនៅរស់នោះមិនអាចបំពេញករណីយកិច្ចជាអ្នកដែលមានអំណាចមេបាបាន ដោយសារមូលហេតុដូចជាឪពុក ឬម្តាយដែលនៅរស់នោះបានរៀបអាពាហ៍ពិពាហ៍សាជាថ្មីជាអាទិ៍ ឪពុក ឬម្តាយនោះត្រូវលាឈប់ពីការធ្វើជាអ្នកដែលមានអំណាចមេបា។ ក្នុងច្បាប់ក៏ដូចជានៅក្នុងសង្គមផងដែរ កុមារត្រូវបានចាត់ទុកជាវ័យទន់ខ្សោយខាងប្រាជ្ញា និងការគិតគូរពិចារណាដែលធ្វើឲ្យអ្នកដ៏ទៃងាយស្រួលធ្វើបាប និងកេងប្រវ័ញ្ច ដូច្នេះហើយទើបកុមារទាមទារឲ្យឋិតក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ។ ហេតុដូច្នេះទើបមានបញ្ហាមួយចោទឡើងថាក្នុងករណីបើឪពុក ឬម្តាយដែលមានអំណាចមេបាទោលត្រូវបានទទួលមរណៈហើយឪពុក ឬម្តាយដែលនៅរស់បានរៀបអាពាហ៍ពិពាហ៍ថ្មី តើកូនដែលជាអនីតិជនត្រូវឋិតក្រោមការគ្រប់គ្រង់ថែទាំរបស់អ្នកណា?

ជាការពិតណាស់នៅក្នុងករណីនេះ គឺជាស្ថានភាពដែលខ្វះអ្នកមានអំណាចមេបាសម្រាប់កូនដែលជាអនីតិជន ហើយស្ថានភាពនេះបានធ្វើឲ្យប៉ះពាល់ដល់សុខុមាលភាពរបស់កូន ដូច្នេះដើម្បីសង្គ្រោះករណីនេះត្រូវមានការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន។[59] ដោយហេតុថាការព្យួរសិទ្ធិអំណាចមេបារបស់អ្នកដែលមានអំណាចមេបាត្រូវធ្វើឡើងតាមរយៈតុលាការ តុលាការនឹងអាចដឹងថាអនីតិជននឹងពុំមានអ្នកដែលមានអំណាចមេបា ហេតុដូច្នេះដើម្បីបីបាច់ថែរក្សារូបកាយកូន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនជំនួសអ្នកមានអំណាចមេបាតុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនដោយឆន្ទានុសិទ្ធិរបស់ខ្លួន។[60] របបគ្រប់គ្រងដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជន គឺមានយន្តការមួយដែលជារបបគ្រប់គ្រងដោយជនមួយរូបដែលតុលាការបានជ្រើសតាំងដើម្បីមកគ្រប់គ្រងលើក្មេងដែលពុំមានអំណាចមេបាគ្រប់គ្រង និងមានជនមួយរូបទៀតដែលមានតួនាទីត្រួតពិនិត្យលើអ្នកអាណាព្យាបាលនោះមួយទៀត ។

[58] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥១ កថាខណ្ឌទី៣។

[59] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៦៧។

[60] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥២ កថាខណ្ឌទី២។

អាណាព្យាបាលមានសិទ្ធិ និងករណីយកិច្ចដូចទៅនឹងឳពុកម្តាយបង្កើតរបស់ក្មេងដែរ ពោលគឺការចិញ្ចឹមថែរក្សា អប់រំ នៃរបបអាណាព្យាបាលសម្រាប់អនីតិជន គឺជាការអប់រំថែរក្សាទូន្មានប្រៀនប្រដៅ ការពារ និងផ្តល់ផលប្រយោជន៍ដល់ក្មេងដែលឋិតក្រោមការគ្រប់គ្រងដោយរបបនេះ។[61] ភាពខុសប្លែកគ្នារវាងការផ្តល់អាហារកាតព្វកិច្ចដល់កូនដែលនៅក្រោមការមើលថែរបស់ឳពុកម្តាយ និងក្មេងដែលឋិតក្រោមការគ្រប់គ្រងថែរក្សារបស់អាណាព្យាបាលសម្រាប់អនីតិជនមានភាពខុសគ្នាត្រង់ ឳពុកម្តាយមានតួនាទីផ្តល់ឲ្យកូននូវការផ្គត់ផ្គង់ទ្រព្យសម្បត្តិក៏ដូចជាលុយកាក់ ចំនែកឯក្មេងដែលបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយអាណាព្យាបាលវិញគឺអ្នកអាណាព្យាបាលពុំមានកាតព្វកិច្ចផ្តល់ដល់ក្មេងនោះទេ ប៉ុន្តែអ្នកជាអាណាព្យាបាលត្រូវទទួលបានកំរៃសាច់ប្រាក់ ឬជាទ្រព្យសម្បត្តិណាមួយរបស់ក្មេងតាមការវិនិច្ឆ័យរបស់តុលាការ។[62] តុលាការអាចសំរេចឱ្យនូវកំរៃមួយដល់អ្នកអាណាព្យាបាលដ៏សមរម្យដោយពិនិត្យមើលទៅតាមលទ្ធភាពនៃជីវភាពរបស់ក្មេង ដើម្បីជាថ្នូរដូរនឹងការគ្រប់គ្រងថែរក្សាដ៏ល្អរបស់អ្នកអាណាព្យាបាលសំរាប់ក្មេងនោះ។

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិវិញ អ្នកអាណាព្យាបាលមានតួនាទីគ្រប់គ្រងជាអ្នកតំណាងឲ្យក្មេងដូចជាការចុះកិច្ចសន្យាលក់ទិញ ភតិសន្យា ដើម្បីឲ្យមានសុពលភាពព្រោះថាអនីតិជនពុំមានសិទ្ធិចុះកិច្ចសន្យាដើម្បីមានសុពលភាពតាមច្បាប់នោះទេ។[63] ចំពោះករណីអាណាព្យាបាលរស់នៅជាមួយនឹងក្មេងដើម្បីផ្តល់ភាពងាយស្រួលគ្រប់គ្រង និងថែរក្សាក្មេងតម្រូវឱ្យមានធ្វើការស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជនដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិរបស់អនីតិជន។ ការកំណត់អំពីកាតព្វកិច្ចក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌដល់អ្នកអាណាព្យាបាលសម្រាប់អនីតិជនគឺមានគោលបំណងដើម្បីធ្វើការបែងចែកអោយដាច់ពីគ្នារវាងទ្រព្យសម្បត្តិរបស់អនីតិជន និងទ្រព្យសម្បត្តិអ្នកអាណាព្យាបាល។ អ្នកអាណាព្យាបាលត្រូវចាប់ផ្តើមធ្វើការស្រាវជ្រាវពីចំនួនទ្រព្យសម្បត្តិទាំងអស់របស់អនីតិជនដោយគ្មានការយឺតយ៉ាវ និងត្រូវបញ្ចប់ការស្រាវជ្រាវក្នុងរយៈពេល៣(បី)ខែចាប់តាំងពីពេលបានក្លាយជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន។[64]ការបញ្ចប់របបអាណាព្យាបាលសម្រាប់អនីតិជនមិនខុសពីការបញ្ចប់អំណាចមេបាទេ មានន័យថាការដល់នីតិភាពរបស់អនីតិជនគឺជាមូលដ្ឋានចំបងដែលធ្វើឱ្យរួចផុតពីរបបនៃការគ្រប់គ្រងរបបអាណាព្យាបាលសម្រាប់អនីតិជន។

[61] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៧៩ កថាខណ្ឌទី១។
[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៨៨។
[63] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៨០។
[64] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៨១ កថាខណ្ឌទី១។

## ផ្នែកទី២៖ ការព្យួរ និងការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

ជាការពិតណាស់ទោះបីជាអ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូនក៏ពិតមែន ក៏ប៉ុន្តែមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ ឬយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួននូវទ្រព្យសម្បត្តិរបស់កូនសម្រាប់ផលប្រយោជន៍របស់ខ្លួន ឬរបស់តតិយជន ឬគេងបន្លំធ្វើឲ្យចុះអន់ថយតាមរយៈការគ្រប់គ្រងមិនស្មោះត្រង់ឡើយ។ ពោលគឺអ្នកមានអំណាចមេបាត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដោយការប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត។[65]

ក្នុងករណីប្រសិនបើអ្នកមានអំណាចមេបាធ្វើសកម្មភាពបំពានលើករណីខាងលើ គេអាចធ្វើការព្យួរ ឬដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបានតាមផ្លូវតុលាការបាន ប៉ុន្តែក្នុងករណីការបំពាននេះត្រូវបានបញ្ចប់ តុលាការអាចលុបចោលការព្យួរដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិតាមការទាមទាររបស់សាមីជនដែលបានទទួលការព្យួរទោស ឬដកហូតសិទ្ធិអំណាចនការគ្រប់គ្រងទ្រព្យសម្បត្តិ ឬញាតិ៤ថ្នាក់របស់ជននោះ។[66] ម្យ៉ាងទៀតអ្នកមានអំណាចមេបាមិនត្រូវធ្វើសកម្មភាពដែលផលប្រយោជន៍របស់ខ្លួន និងកូនផ្ទុយគ្នានោះទេ ដូចជាអ្នកមានអំណាចមេបាទិញអចលនវត្ថុរបស់កូន ឬដាក់អចលនវត្ថុរបស់កូនជាប្រាតិភោគដើម្បីធានាកាតព្វកិច្ចរបស់ខ្លួនជាអាទិ៍។ ក្នុងករណីអ្នកមានអំណាចមេបាមានបំណងធ្វើសកម្មភាពដែលបណ្តាលឱ្យ ឬអាចបណ្តាលឱ្យមានភាពផ្ទុយគ្នានផលប្រយោជន៍រវាងខ្លួន និងកូនដូចនេះអ្នកមានអំណាចមេបាត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់កូន។[67] បើពុំដូច្នេះទេសកម្មភាពដែលអ្នកមានអំណាចមេបាបានប្រព្រឹត្តគឺជាការតំណាងដែលគ្មានសិទ្ធិ ហើយសកម្មភាពនោះពុំបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិ(កូន)ទេ មានន័យថា កូនអាចយកអចលនវត្ថុនោះវិញពីអ្នកមានអំណាចមេបាដោយអះអាងអំពីមោឃភាពនៃកិច្ចសន្យាលក់ ទិញ។

ជាទូទៅនៅពេលដែលអំណាចមេបាបានបញ្ចប់ ការគ្រប់គ្រងដែលទាក់ទងនឹងកូន និងការគ្រប់គ្រងទ្រព្យសម្បត្តិក៏ត្រូវបានបញ្ចប់ ហើយទាក់ទងនឹងការបញ្ចប់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនអ្នកមានអំណាចមេបាត្រូវគណនាចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដោយគ្មានការយឺតយ៉ាវ (អំឡុងពេលសមរម្យដែលឆ្លើយតបនឹងស្ថានភាពជាក់ស្តែង)។ នៅក្នុងអំឡុងពេលនៃការអនុវត្តអំណាចមេបាអ្នកមានអំណាចមេបាបានចំណាយសោហ៊ុយជាច្រើនទាក់ទងនឹងការចិញ្ចឹមកូន មូករួមទាំងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ប៉ុន្តែការចិញ្ចឹមកូនគឺជាករណីយកិច្ចរបស់អ្នកមានអំណាចមេបា ហេតុនេះពុំសមរម្យឡើយក្នុងការឱ្យកូនបង់សង

[65] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥៥។

[66] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៦២។

[67] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៦៥ កថាខណ្ឌទី១។

មកវិញ។[68] ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយច្បាប់បានកំណត់ថាបើអ្នកមានអំណាចមេបាបានទទួលចំណូលពីទ្រព្យសម្បត្តិរបស់កូនត្រូវចាត់ទុកថាជាការទូទាត់នឹងសោហ៊ុយចិញ្ចឹមបីបាច់កូន និងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន។ មានន័យថានៅក្នុងអំឡុងពេលអនុវត្តអំណាចមេបា អ្នកមានអំណាចមេបាអាចអាស្រ័យផលពីទ្រព្យសម្បត្តិរបស់កូនបានគឺផលដែលទទួលបានពីទ្រព្យសម្បត្តិនោះដូចជាថ្លៃឈ្នួលជាអាទិ៍ អ្នកមានអំណាចមេបាមិនចាំបាច់ប្រគល់ឱ្យកូននៅពេលដែលកូនមាននីតិភាពទេ។

ផ្ទុយទៅវិញចំពោះទ្រព្យសម្បត្តិបានផ្តល់មកពីប្រទានកម្ម ហើយអ្នកផ្តល់ឲ្យនោះបានបង្ហាញឆន្ទៈមិនឱ្យអ្នកមានអំណាចមេបាអាស្រ័យផលពីទ្រព្យសម្បត្តិនោះ ដូចនេះអ្នកមានអំណាចមេបាមិនអាចអាស្រ័យផលពីទ្រព្យសម្បត្តិនោះបានឡើយ មានន័យថាចំណូលដែលទទួលបានពីទ្រព្យសម្បត្តិរបស់កូនត្រូវប្រគល់ឱ្យកូននៅពេលដែលកូនដល់នីតិភាព។ ម្យ៉ាងវិញទៀតនៅក្នុងករណីអ្នកមានអំណាចមេបាបានចាត់ចែងលក់ទ្រព្យសម្បត្តិរបស់កូនជាអាទិ៍ នៅពេលដែលកូនមាននីតិភាពប្រាក់ដែលបានមកពីការលក់នេះត្រូវប្រគល់អោយកូន ប៉ុន្តែប្រសិនបើអ្នកមានអំណាចមេបាមិនបានប្រគល់ប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិរបស់កូនទេ កូនមានសិទ្ធិទាមទារឱ្យអ្នកមានអំណាចមេបាប្រគល់ដែលអំឡុងពេលនៃការទាមទារនោះគឺ៣(បី)ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិអំណាចនៃការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់។

ករណីដែលសិទ្ធិអំណាចរបស់អ្នកមានអំណាចមេបាក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានរលត់ នៅក្នុងពេលដែលកូនពុំទាន់ដល់នីតិភាព ប្រសិនបើកូនពុំទាន់មានអ្នកតំណាងដែលច្បាប់បានកំណត់(អ្នកមានអំណាចមេបាថ្មី) អំឡុងពេលនៃការទាមទារគឺ៣(បី)ឆ្នាំ គិតចាប់ពីពេលដែលកូននោះបានដល់នីតិភាព ឬពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានកាន់តំណែង។ ទោះបីជាអំណាចមេបាត្រូវបានបញ្ចប់ដោយសារតែកូនបានដល់នីតិភាព ឬសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានព្យួរ ឬដកហូតក៏ដោយក៏អ្នកមានអំណាចមេបានៅតែបន្តគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូនដដែលរហូតដល់កូនមានអ្នកគ្រប់គ្រងថ្មីមានលទ្ធភាពចាប់ផ្តើមគ្រប់គ្រងទ្រព្យសម្បត្តិនោះព្រោះទ្រព្យសម្បត្តិនឹងស្ថិតក្នុងហានិភ័យ បើអ្នកមានអំណាចមេបាលែងគ្រប់គ្រងទ្រព្យសម្បត្តិនោះភ្លាមមុនពេលដែលកូន ឬអ្នកគ្រប់គ្រងថ្មីមិនទាន់មានលទ្ធភាពចាប់ផ្តើមគ្រប់គ្រងទ្រព្យសម្បត្តិ។[69]

## ផ្នែកទី៣៖ ការបញ្ចប់អំណាចមេបា

ការបញ្ចប់អំណាចមេបាសំដៅទៅដល់ការបញ្ចប់សិទ្ធិ និងករណីយកិច្ចរបស់អ្នកអំណាចមេបាលើការចិញ្ចឹមបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ។ មានន័យថាឪពុក

[68] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៥៦ វាក្យខណ្ឌទី២។
[69] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា១០៦០ វាក្យខណ្ឌទី២។

ឬម្ដាយមិនមានករណីយកិច្ចចិញ្ចឹមបីបាច់ថែរក្សា និងគ្រប់គ្រងកូនបន្តទៀតឡើយដោយហេតុថាការកូនបានក្លាយជាបុគ្គលដែលមានសមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។

អំណាចមេបាត្រូវបានបញ្ចប់នៅពេលដែលកូនបានដល់នីតិភាព មានន័យថានៅពេលដែលកូនមានអាយុគ្រប់តាមការកំណត់របស់ច្បាប់ សំដៅដល់នីតិជនដែលមានអាយុចាប់ពី១៨(ដប់ប្រាំបី)ឆ្នាំ ឡើងទៅដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាព មានន័យថាបុគ្គលដែលជានីតិជនអាចធ្វើការសកម្មភាពដោយឯករាជ្យដោយខ្លួនឯងបានមិនចាំបាច់ត្រូវមានការយល់ព្រមពីអ្នកមានអំណាចមេបាទៀតឡើយ។

ជាមួយគ្នានេះដែរកូនអាចរួចផុតពីអំណាចមេបាបាន ទោះបីជាកូននោះមិនទាន់គ្រប់អាយុតាមកំណត់របស់ច្បាប់ក៏ដោយ ក្នុងករណីដែលកូនបានទទួលអត្តាធីនភាពគឺក្នុងករណីដែលអនីតិជនដែលបានដល់អាយុចាប់ពី១៦(ដប់ប្រាំមួយ)ឆ្នាំឡើងទៅ ហើយអាចទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យមិនចាំបាច់ពឹងពាក់នរណាឡើយ តុលាការអាចប្រកាសនូវអត្តាធីនភាពបានតាមពាក្យសុំរបស់អនីតិជននោះ[70] ប្រសិនបើតុលាការយល់ឃើញថាអត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជន។

ម្យ៉ាងទៀតតុលាការត្រូវសួរយោបល់ពីអ្នកមានអំណាចមេបាផងដែរ ដោយសារអនីតិជនទទួលបានអត្តាធីនភាពមិនចាំបាច់មានការប្រកាសពីតុលាការទេ ដោយផ្អែកលើមូលហេតុនៃការរៀបអាពាហ៍ពិពាហ៍។[71] អនីតិជនដែលមានគំនិតចាស់ទុំអាចរៀបអាពាហ៍ពិពាហ៍បាន គេអាចចាត់ទុកជាអនីតិជនម្នាក់ដែលអាចប្រកបកិច្ចការជួញដូរបានដូច្នេះត្រូវទទួលបានអត្តាធីនភាព និងរួចផុតពីអំណាចមេបាដើម្បីធានានូវឯករាជ្យភាពនៃអាពាហ៍ពិពាហ៍នោះ។ អត្តាធីនភាពគឺមានអានុភាពអាចធ្វើឱ្យច្បាប់ចាត់ទុកថាអនីតិជននោះបានដល់នីតិភាពហើយក្លាយជាជនដែលមានសិទ្ធិដូចនីតិជនដែលមានអាយុគ្រប់១៨(ដប់ប្រាំបី)ឆ្នាំ និងអាចធ្វើសកម្មភាពបានដូចជានីតិជនផងដែរ។ ដោយសារតែអានុភាពនេះអនីតិជននោះអាចធ្វើសកម្មភាពពាណិជ្ជកម្ម ដូចជាការបើកអាជីវកម្មផ្ទាល់ខ្លួនដោយមិនចាំបាច់មានការអនុញ្ញាតពីម្ដាយឪពុក(អ្នកដែលមានអំណាចមេបា) ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ អនីតិជនព្រមទាំងអាចធ្វើសកម្មភាពតាមកិច្ចសន្យាដោយអាចបង្កើត កែប្រែ និងរំលត់កាតព្វកិច្ចបាន និងអាចធ្វើនូវសកម្មភាពឯកតោភាគីបានថែមទៀត។ លើសពីនេះទៅទៀតអនីតិជនអាចទទួលបាននូវបុគ្គលភាពគតិយុត្ត(ភាពជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច) យ៉ាងពេញលេញទៀតផង។

ថ្វីត្បិតតែអំណាចមេបាត្រូវបានបញ្ចប់ដោយសារតែកូនដល់នីតិភាពក៏ពិតមែន ក៏មិនប្រាកដថាកូនអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិ ឬកិច្ចការមួយចំនួនដោយឯកឯងបាននោះដែរព្រោះកិច្ចការគ្រប់គ្រងទ្រព្យសម្បត្តិមួយចំនួនកន្លងមកជាករណីយកិច្ចរបស់អ្នកមានអំណាចមេបា ដែលកូនមិនបានធ្វើ

[70] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា២១ កថាខណ្ឌទី១។

[71] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា២១ កថាខណ្ឌទី២។

សកម្មភាពគ្រប់គ្រងទ្រព្យសម្បត្តិទាំងនេះពីមុនមកទេ ជាហេតុនាំឱ្យកូនមិនអាចមានលទ្ធភាពក្នុងការគ្រប់គ្រងចាត់ចែងបានភ្លាមៗ។

ដូច្នេះប្រសិនបើមានការបញ្ចប់អំណាចមេបា ហើយអ្នកមានអំណាចមេបាធ្វើការបញ្ចប់លើការគ្រប់គ្រងទ្រព្យសម្បត្តិភ្លាមៗ ប្រាកដណាស់ទ្រព្យសម្បត្តិដែលគាត់ធ្លាប់ធ្វើការគ្រប់គ្រងនោះនឹងត្រូវរងការខូចខាតដែលកើតឡើងដោយហេតុការណ៍ណាមួយដែលមិនអាចព្យាករណ៍បាន ដោយហេតុថាក្នុងអំឡុងពេលនោះកូនមិនអាចយល់ដឹងអំពីរបៀបនៃការគ្រប់គ្រងជាដើម។ ការអនុវត្តនេះនឹងត្រូវបានអនុវត្តដូចគ្នាផងដែរក្នុងករណីដែលមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងថ្មីដោយមូលហេតុមានការព្យួរ ឬដកហូតអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ គឺអ្នកដែលមានអំណាចមេបាមិនអាចធ្វើការបញ្ចប់ការគ្រប់គ្រងភ្លាមៗបានឡើយ។[72]

[72] សៀវភៅអ្នកមានអំណាចមេបា, លោកស្រី នូ ច័ន្ទសុគន្ធា។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងការបកស្រាយនូវប្រធានបទស្តីអំពីអំណាចមេបា ខាងលើរួចមកយើងអាចសន្និដ្ឋានបានថាចំណងគតិយុត្តរវាងឪពុកម្តាយ និងកូនបានឆ្លុះបញ្ចាំងអំពីទំនួលខុសត្រូវរបស់អ្នកជាឪពុកម្តាយ ឬអ្នកមានសិទ្ធិគ្រប់គ្រងកូនដែលត្រូវមានចំពោះកូនដែលជាអនីតិជន។ ជាទូទៅក្នុងនាមជាឪពុកម្តាយត្រូវមានទំនួលខុសត្រូវចំពោះកូនចាប់តាំងពីកូនចាប់កំណើតក្នុងផ្ទៃរហូតដល់កូនគ្រប់នីតិភាព។ អំណាចមេបាគឺជាសិទ្ធិអំណាចរបស់ឪពុកម្តាយ ក្នុងន័យនេះចង់សំដៅដល់ឪពុកម្តាយត្រូវមានតួនាទីក្នុងការចិញ្ចឹមបីបាច់ថែរក្សារូបកាយរបស់អនីតិជនដែលជាកូនរបស់ខ្លួន និងក្នុងការគ្រប់គ្រងនូវទ្រព្យសម្បត្តិជារបស់កូនជាអនីតិជននោះ។ ទោះបីជាអនីតិជនមិនអាចរកចំណូលបានពិតមែន ប៉ុន្តែគាត់អាចទទួលបានអំណោយ ប្រទានកម្មពីអ្នកដទៃឬក៏ជាមរតកដោយសារតែអនីតិជនគាត់អសមត្ថភាពក្នុងការគ្រប់គ្រងនៅឡើយ ដូចនេះឪពុកម្តាយចាំបាច់ត្រូវការគ្រប់គ្រងត្រួតពិនិត្យក្នុងការសម្រេចបន្ថែម និងការពារផលប្រយោជន៍របស់កូនដោយសហការគ្នា។

ជាធម្មតាអ្នកដែលមានអំណាចមេបាលើកូនមានតែឪពុកម្តាយក៏ពិតមែន ដោយគេសំដៅទៅលើឪពុកម្តាយបង្កើត តែក៏មានករណីពិសេសមួយចំនួនដូចជាឪពុកម្តាយចិញ្ចឹមដោយសារតែច្បាប់ក៏បានអនុញ្ញាតអោយមានការសុំកូនផងដែរ។ ការសុំកូនគេមានការបែងចែកជាពីរប្រភេទដែលក្នុងនោះមានការសុំកូនពេញលេញ និងការសុំកូនធម្មតា។ ការសុំកូនពេញលេញគឺមានការផ្តាច់ទំនាក់ទំនងរវាងឪពុកម្តាយបង្កើតជាមួយនឹងកូន ដូច្នេះហើយអំណាចមេបាគឺធ្លាក់ទៅលើឪពុកម្តាយចិញ្ចឹម។ ឯទំនាក់ទំនងក្នុងការសុំកូនធម្មតាវិញគឺទំនាក់ទំនងរវាងឪពុកម្តាយបង្កើត និងកូននៅតែរក្សាដដែល ដោយសារតែការសុំកូនធម្មតាគឺយកកូនទៅចិញ្ចឹមថែរក្សាដោយផ្ទាល់ដូចនេះហើយអ្នកដែលបីបាច់ដោយផ្ទាល់ត្រូវតែមានអំណាចមេបាចំពោះកូននោះ ដូចនេះទើបឪពុកម្តាយចិញ្ចឹមអាចអនុវត្តន៍សិទ្ធិរបស់គាត់បាន ហើយកូនក៏ទទួលបានផលប្រយោជន៍របស់ខ្លួនបានពេញលេញដូចគ្នា។ កាលណាបើឪពុកម្តាយទទួលបានអំណាចមេបាហើយគឺគាត់មានសិទ្ធិ និងករណីកិច្ចចំពោះកូន ហើយសិទ្ធិនិងករណីកិច្ចរបស់ឪពុកម្តាយ គឺជាសិទ្ធិនិងករណីកិច្ចជាសាធារណៈដែលរដ្ឋបានដាក់កាតព្វកិច្ចចំពោះឪពុកម្តាយជាក់ស្តែងនៅក្នុងរដ្ឋធម្មនុញ្ញបានកំណត់ថាមាតាបិតាត្រូវមានករណីកិច្ចក្នុងការអប់រំ ចិញ្ចឹមបីបាច់ថែរក្សាកូនឱ្យបានក្លាយទៅជាពលរដ្ឋល្អក្នុងនោះមានរួមទាំងការអប់រំ ការដាក់ទណ្ឌកម្ម ការផ្តល់ទីសំណាក់ ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈឬអាជីវកម្ម និងសិទ្ធិក្នុងការទាមទារកូនត្រលប់មកវិញប្រសិនបើការយកទៅនោះដោយគ្មានការអនុញ្ញាតពីអ្នកមានអំណាចមេបា។ បើឪពុកម្តាយបានបែកបាក់ចំណងអាពាហ៍ពិពាហ៍នោះនាំអោយមានផលពិបាកចំពោះកូន ដូចនេះភាគីទាំងពីរត្រូវតែមានការពិចារណាពិភាក្សាគ្នាអំពីការកំណត់យកឪពុក ឬម្តាយណាម្ខាងជាអំណាចមេបាទោល។ ប៉ុន្តែក្នុងករណីដែលការពិភាក្សានោះភាគីទាំងពីរមិនបានព្រមព្រៀងនឹងគ្នាទេ ភាគីទាំងពីរអាចរើសយកអំណាចតុលាការក្នុងការបែងចែកសិទ្ធិអំណាចមេបារបស់កូន ដោយតុលាការនឹងមើលទៅ

លើចំណុចមួយចំនួនដូចជាប្រាក់ចំណូលរបស់ភាគីទាំងសងខាង ទីស្នាក់អាស្រ័យដែលអំណោយផលដល់កូនជាង និងអាកប្បកិរិយាអត្តចរិករបស់ម្ដាយឪពុក ហើយតុលាការនឹងធ្វើការវិនិច្ឆ័យរកចំណុចរួមមួយថាភាគីខាងណាដែលអាចផ្ដល់ប្រយោជន៍អោយកូនជាង។ចំណងគតិយុត្តរវាងឪពុក ឬម្ដាយដែលពុំបានទទួលសិទ្ធិអំណាចមេបា និងកូននៅតែរក្សាដដែលដោយគាត់នៅតែមានសិទ្ធិធ្វើការប្រាស្រ័យទាក់ទងគ្នាជាមួយកូនដោយគាត់អាចដឹងពីស្ថានភាពរបស់កូនជាមួយគ្នានេះដែរគាត់នៅតែមានសិទ្ធិ និងករណីកិច្ចចូលរួមទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីការរស់នៅប្រចាំថ្ងៃរបស់កូន។ ចំពោះអ្នកដែលមានអំណាចមេបាចាំបាច់ត្រូវតែផ្ដល់ភាពងាយស្រួលដល់ភាគីម្ខាងទៀតក្នុងការប្រាស្រ័យទាក់ទងជាមួយកូន។

ទោះបីជាឪពុកម្ដាយមានសិទ្ធិអំណាចមេបាក៏ពិតមែន តែបើគាត់បានបំពានសិទ្ធិ និងករណីកិច្ចដែលជាអ្នកមានអំណាចមេបានោះតុលាការអាចប្រកាសការព្យួរ ឬក៏ដកហូតអំណាចមេបានោះបានតាមរយៈការស្នើសុំរបស់ញាតិទាំងបួនថ្នាក់របស់កូន ក៏ដូចជាតាមរយៈការស្នើសុំរបស់មេធាវី, មេឃុំចៅសង្កាត់ ឬតាមរយៈតំណាងអយ្យការផងដែរ។ ការដកហូត ឬការប្រកាសព្យួរអំណាចមេបាគឺជាការដកសិទ្ធិទាំងស្រុង ឬបណ្ដោះអាសន្នក្នុងការគ្រប់គ្រងកូនដែលជាអនីតិជនទៅតាមការស្នើសុំរបស់អ្នកមានសិទ្ធិក្នុងការស្នើសុំ ប្រសិនបើអ្នកដែលមានអំណាចមេបាមិនបានបំពេញកាតព្វកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា។ ក្រោយមកបើបុគ្គលដែលត្រូវបានគេដកហូតឬព្យួរអំណាចមេបាដឹងកំហុសនូវអ្វីដែលខ្លួនបានប្រព្រឹត្តកន្លងមកហើយចង់បានមកវិញនូវអំណាចមេបាបុគ្គលនោះអាចដាក់ពាក្យស្នើសុំទៅតុលាការឱ្យលុបចោលការព្យួរ ឬការដកហូតអំណាច នោះតុលាការនឹងធ្វើការពិចារណាដោយផ្អែកទៅលើប្រយោជន៍របស់កូន។ បើតុលាការសម្រេចថាការព្យួរ ឬការដកហូតអំណាចមេបាបានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសព្យួរ ឬការដកហូតសិទ្ធិអំណាចក្នុងនាមអ្នកមានអំណាចមេបាតាមការទាមទាររបស់សាមីជនដែលបានទទួលការព្យួរឬការដកហូតអំណាចមេបានោះឬញាតិក្នុងបួនថ្នាក់របស់ជននោះបាន។ ប៉ុន្តែក្នុងករណីឪពុកម្ដាយណាម្ខាងពុំអាចប្រើប្រាស់អំណាចមេបាបាន ឬឪពុកម្ដាយណាម្ខាងបានទទួលមរណៈភាព ឪពុកឬម្ដាយម្ខាងទៀតត្រូវក្លាយជាអ្នកដែលមានអំណាចមេបាដោយស្វ័យប្រវត្តិតាមបញ្ញត្តិច្បាប់។ ចំពោះករណីមានការព្យួរ ឬដកហូត និងការលាយឈប់អានុភាពកើតមានឡើងនៅពេលមានសេចក្ដីសម្រេចរបស់តុលាការ។ តែទោះជាយ៉ាងណាមានការចាប់ផ្ដើមក៏មានការបញ្ចប់ទៅដូចគ្នាឪពុកម្ដាយមិនអាចមានអំណាចមេបាទៅលើកូនរហូតនោះទេ អំណាចមេបានឹងបញ្ចប់ទៅវិញនៅពេលដែលកូនគ្រប់នីតិភាពមានន័យថាសិទ្ធិ និងករណីយកិច្ចរបស់អ្នកអំណាចមេបាលើការបីបាច់រក្សារូបកាយរបស់កូនដែលជាអនីតិជននិងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនត្រូវបានបញ្ចប់ ព្រោះកូនមានអាយុគ្រប់តាមការកំណត់របស់ច្បាប់ជាបុគ្គលដែលមានសមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាពដោយឯករាជ្យខ្លួនឯងបានមិនចាំបាច់ត្រូវមានការយល់ព្រមពីអ្នកមានអំណាចមេបាទៀតឡើយ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងតាក់តែងសារណាក្រោមប្រធានបទ "**អំណាចមេបា**" រួចមក យើងខ្ញុំយល់ឃើញថាអ្វីក៏ដោយមិនអាចដូចគោលបំណងដែលយើងចង់បាននោះទេ ទោះបីជាច្បាប់បានកំណត់ព្រំដែននៃសិទ្ធិហើយក៏ដោយ តែការអនុវត្តជាក់ស្តែងរួមជាមួយការរស់នៅក្នុងសង្គមសព្វថ្ងៃ មនុស្សតែងតែប្រព្រឹត្តបំពានទៅលើបទប្បញ្ញត្តិទាំងនោះ ដែលជាហេតុបង្កអោយមានបញ្ហាប្រឈមទៅលើបុគ្គលដែលស្ថិតនៅក្រោមអំណាចមេបាផងដែរ។ ជាលទ្ធផលដើម្បីអោយការអនុវត្តរវាងអ្នកដែលមានសិទ្ធិអំណាចមេបា និងជនដែលស្ថិតនៅក្រោមអំណាចមេបាមានប្រសិទ្ធិភាព តម្លាភាព និងដើម្បីជាប្រយោជន៍រួម យើងខ្ញុំសូមអនុញ្ញាតផ្តល់ជាអនុសាសន៍មតិយោបល់មួយចំនួន ក្នុងគោលបំណងចង់អោយការប្រើប្រាស់សិទ្ធិមានភាពត្រឹមត្រូវ សមស្របទៅនឹងស្ថានភាពជាក់ស្តែង ក៏ដូចជាដើម្បីជៀសវាងនូវហានិភ័យនានាទៅថ្ងៃអានាគតៈ

- នៅតាមទីសាធារណៈមានក្មេងកំព្រា ក្មេងអនាថា ពួកគាត់បានដើរសុំទាន លក់ដូរតាមផ្លូវដោយពួកគាត់ត្រូវបានជនដែលជាអាណាព្យាបាលបោះបង់សិទ្ធក្នុងការទទួលបានការអប់រំ ថែមទាំងបានបង្ខំឱ្យចេញមករកថវិកាចិញ្ចឹមជីវិតថែមទៀតផង កំឡុងពេលដែលកុមារមួយចំនួនទៀតគាត់គ្មានទីលំនៅ គ្មានអ្នកមើលថែ ដូច្នេះរាជរដ្ឋាភិបាលគួរតែពង្រឹងច្បាប់ដាក់ទណ្ឌកម្មទៅលើជនដែលជាអ្នកមានសិទ្ធិអំណាចមេបាហើយបានបំពានសិទ្ធិកុមារទាំងនោះ និងស្វែងរកវិធានការបន្ថែមដើម្បីជាជំនួយជួយដល់កុមារដែលជាជនរងគ្រោះ និងគ្មានទីពឹងផ្សេងៗផងដែរ។ ទោះបីជាបច្ចុប្បន្នមានអង្គការមួយចំនួនបានជួយដល់ក្មេងៗទាំងនោះក្តី តែនៅមានកម្រិតនៅឡើយ ដែលជាហេតុមិនអាចជួយដល់ក្មេងៗដែលកំពុងរងគ្រោះទាំងអស់គ្នាបាន។
- ជាការពិតណាស់អំណាចមេបាមានសម្រាប់កូនដែលជាអនីតិជនតែប៉ុណ្ណោះ មានន័យថានៅពេលដែលកូនគ្រប់នីតិភាពហើយគាត់មិនស្ថិតនៅក្រោមអំណាចមេបាទៀតទេ ឯឪពុកម្តាយក៏លែងមានសិទ្ធិ និងករណីកិច្ចដែលកំណត់ដោយច្បាប់ហើយ។ ប៉ុន្តែនៅក្នុងទំនាក់ទំនងការរស់នៅសព្វថ្ងៃ ទោះបីជាកូនគ្រប់នីតិភាពក៏ដោយ ក៏តែងតែមានការជ្រោមជ្រែងពីឪពុកម្តាយ ដោយសារតែក្តីស្រឡាញ់ គឺគាត់តែងតែជួយកូនបន្ថែម ទោះវាមិនមែនជាកាតព្វកិច្ចកំណត់ដោយច្បាប់ក៏ដោយ តែក្នុងករណីខ្លះឪពុកម្តាយសព្វថ្ងៃក៏នៅតែបិទសិទ្ធិសម្រេចរបស់កូន គ្រប់គ្រងកូនទៅលើការរស់នៅប្រចាំថ្ងៃ ទាំងជីវិតឯកជនរបស់កូន ក៏ដូចជាទ្រព្យសម្បត្តិរបស់កូន ទោះបីជាកូនមានសមត្ថភាពខាងឆន្ទៈក្នុងការធ្វើសកម្មភាពក៏ដោយ នេះជាហេតុធ្វើអោយកូនរស់នៅគ្មានភាពឯករាជ្យក៏ដូចជាផ្តល់សម្ពាធក្នុងការរស់នៅប្រចាំថ្ងៃរបស់កូន។
- រូបភាពការដាក់ទណ្ឌកម្មលើសច្បាប់កំណត់មានលេចឡើងច្រើន ការដាក់ទណ្ឌកម្មជាសិទ្ធិរបស់ឪពុកម្តាយក៏ពិតមែន តែក៏ត្រូវបានកម្រិតថាការដាក់ទណ្ឌកម្មធ្វើយ៉ាងណាកុំអោយប៉ះពាល់ដល់បញ្ញាស្មារតី

ដល់រូបរាងកាយ ក៏ដូចជាសុខភាពរបស់កូនជាអនីតិជន។ យើងអាចធ្វើឡើងត្រឹមការស្តីបន្ទោស ឬការដាក់ទណ្ឌកម្មបែបចូលរួមជួយអោយកូនមានការអភិវឌ្ឍខ្លួនដូចជាដាក់វិន័យអោយអាន ឬសរសេរសៀវភៅអោយចប់។

– ចំពោះការអនុញ្ញាតធ្វើអាជីវកម្ម និងការប្រកបវិជ្ជាជីវៈ អនីតិជនគាត់នៅក្មេងក៏ពិតមែនប៉ុន្តែគាត់ក៏មានគំនិតសមត្ថភាពខ្ពស់ក្នុងការអភិវឌ្ឍខ្លួនផងដែរ គាត់អាចរកចំណូលបានតាមរយៈការប្រកបវិជ្ជាជីវៈ ឬអាជីវកម្មណាមួយ តែឪពុកម្តាយត្រូវធ្វើការឃ្លាំមើល និងត្រួតពិនិត្យបន្ថែមថាតើអាជីវកម្ម ឬវិជ្ជាជីវៈនោះមានគុណវិបត្តិចំពោះកូនឬអត់? ដូចជាប៉ះពាល់ដល់ការសិក្សា ដល់បញ្ញាស្មារតីរបស់កូន ឬប៉ះពាល់ដល់អ្នកដទៃឬអត់?

ជាទីបញ្ចប់ អំណាចមេបា ពិតជាមានសារៈសំខាន់ណាស់សម្រាប់កុមារ ព្រោះអ្នកដែលមានអំណាចមេបា គឺត្រូវរ៉ាប់រងចំពោះជីវភាពទាំងស្រុងរបស់កូន ដូច្នេះរាល់ការលូតលាស់ រួមទាំងការហូបចុក សម្លៀកបំពាក់ ការស្នាក់នៅ ការសិក្សារៀនសូត្រ និងការចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីកើតរហូតដល់ធំដឹងក្តីគឺជាកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនអាចខ្វះបាន។ អ្នកដែលមានអំណាចមេបាជាអ្នកបណ្តុះបណ្តាលអោយកុមារក្លាយជាទំពាំងស្នងឬស្សី ជាធនធានល្អក្នុងសង្គម ដូចនេះរដ្ឋត្រូវតែបង្កើននីតិវិធានការទាំងឡាយដែលទាក់ទងនឹងការការពារផលប្រយោជន៍របស់អនីតិជនអោយបានល្អ។ ម្យ៉ាងឪពុកម្តាយដែលជាអ្នកមានសិទ្ធិអំណាចមេបាត្រូវគិតអោយមានអត្ថិភាពបំផុតអំពីផលប្រយោជន៍របស់កូន ហើយត្រូវអនុវត្តន៍ករណីកិច្ចដែលច្បាប់ធានាអោយជាអប្បបរិមា ជាពិសេសគឺការអប់រំ ការរស់នៅប្រចាំថ្ងៃរបស់កូន ព្រោះកុមារគឺជាក្តីរំពឹងតែមួយគត់សម្រាប់ប្រទេសជាតិនាពេលអនាគត ជៀសវាងការប្រើសិទ្ធិអំណាចមេបាលើសកំណត់ ហើយលើកយកធ្វើជាលេសក្នុងការអប់រំកូន។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ កក្កដា ២០០៦។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៥១១០០៧ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ២០០៩ ។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ នៅថ្ងៃទី០៨ មិថុនា ២០១០។

## ២. សៀវភៅ និងស្នាដៃនិពន្ធ

- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, សន្ទានុក្រមបារាំង ខ្មែរនៃពាក្យច្បាប់ (ភ្នំពេញ៖ ហ្វូណន ២០០៥), ទំព័រទី២៩
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ ឆ្នាំ២០០៩-២០១០។
- សៀវភៅអ្នកមានអំណាចមេបា, លោកស្រី នូ ច័ន្ទសុគន្ធា។

## ៣. គេហទំព័រ

- ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ ការដកហូត និងការព្យួរអំណាចមេបា, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០។
- ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, កម្មវិធីយល់ដឹងពីច្បាប់៖ អំណាចមេបា, ថ្ងៃទី៩ ខែធ្នូ ឆ្នាំ ២០២០។

# ឧបសម្ព័ន្ធ

# តារាងបញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះ | លេខឧបសម្ព័ន្ធ |
|---|---|---|
| ១ | ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ធ្នូ ២០០៧។ | ឧបសម្ព័ន្ធទី១ |
| ២ | ឯកសារទាក់ទងនឹងដីកាសម្រេចស្នុំកូនពេញលេញ (ការអនុវត្តជាក់ស្តែង) | ឧបសម្ព័ន្ធទី២ |
| ៣ | ឯកសារទាក់ទងនឹងដីកាសម្រេចលែងលះដោយការព្រមព្រៀង (ការអនុវត្តជាក់ស្តែង) | ឧបសម្ព័ន្ធទី៣ |
| ៤ | ឯកសារទាក់ទងនឹងសាលក្រមលែងលះតាមពាក្យបណ្តឹង (ការអនុវត្តជាក់ស្តែង) | ឧបសម្ព័ន្ធទី៤ |

| ឧបសម្ព័ន្ធទី១ | ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ធ្នូ ២០០៧ |
|---|---|

## ព្រះរាជក្រម

នស/រកម/១២០៧/០៣០

### យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

### ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស្មុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្តឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្តាយចិញ្ចឹម ។

**មាត្រា ១០៣២.–** អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា

១-អានុភាពទាំងឡាយនៃស្មុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនស្មុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.–** ការចុះបញ្ជីនៃស្មុំកូនធម្មតា និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតស្មុំកូនធម្មតា ត្រូវសរសេរការបង្កើតស្មុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

## ជំពូកទី ៥
## អំណាចមេបា

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១០៣៤.–** អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវបីបាច់រក្សារូបកាយ

របស់កូនដែលជាអនីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ។

**មាត្រា ១០៣៥.–** អំណាចមេបាលើកូនសុំ

អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣៦.–** គោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបា

ឪពុកម្ដាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ។ ប៉ុន្តែ បើឪពុក ឬ ម្ដាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬ ម្ដាយម្ខាងទៀតត្រូវប្រើអំណាចមេបានោះ ។

## ផ្នែកទី ២

## ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នា និង ការទទួលស្គាល់

**មាត្រា ១០៣៧.–** ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា

១-បើឪពុកម្ដាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្ដាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយ ។

២-ក្នុងករណីដែលឪពុកម្ដាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្ដាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយបាន ។

៣-បើការពិភាក្សានៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០៣៨.–** ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា

១-អ្នកមានអំណាចមេបាលើកូន ដែលម្ដាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍បានបង្កើត គឺម្ដាយ ។

២-ឪពុក អាចប្រើប្រាស់អំណាចមេបា ចំពោះកូនដែលខ្លួនបានទទួលស្គាល់បាន

តែក្នុងករណីដែលការពិភាក្សារបស់ឪពុកម្ដាយ បានកំណត់យកឪពុកនោះ ជាអ្នកមានអំណាចមេបា ។

៣-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សានោះបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា តាមការទាមទាររបស់ឪពុក ឬ ម្ដាយ ។

៤-ក្រោយពេលដែលឪពុកបានទទួលស្គាល់កូនហើយ ប្រសិនបើឪពុកម្ដាយបានរៀបអាពាហ៍ពិពាហ៍ ឪពុកម្ដាយត្រូវអនុវត្តអំណាចមេបា ដោយសហការគ្នា ។

**មាត្រា ១០៣៩.–** ការផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា

នៅក្នុងករណីនៃបញ្ញត្តិមាត្រា ១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា) និង មាត្រា ១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា) ខាងលើនេះ តុលាការអាចផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូនបាន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ។

**មាត្រា ១០៤០.–** សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្ដាយដែលមិនរស់នៅជាមួយកូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ។

២-ឪពុកម្ដាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ។

៣-ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និង កំណត់ ជាមួយម្ដាយ អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនបាន ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ

ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ ។

៥-បើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចផ្លាស់ប្ដូររបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ បាន ។

៦-នៅក្នុងការសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះ តុលាការត្រូវកំណត់អំពីការចូលជួប ប្រាស្រ័យទាក់ទង ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព និង ត្រូវកំណត់អំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយ ។

៧-ប្រសិនបើឪពុក ឬ ម្ដាយ មិនអាចពិភាក្សា ឬ មិនអាចទាមទារទៅតុលាការបានទេ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះបាន ។

**មាត្រា ១០៩១.–** សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបាលើកូន អាចទាមទារឱ្យអ្នកដែលមានអំណាចមេបា រាយការណ៍អំពីស្ថានភាពរបស់កូននោះបាន ។

២-ចំពោះខ្លឹមសារ និង របៀបរបបនៃការរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់តាមការពិភាក្សារវាងឪពុកម្ដាយ ។ ប៉ុន្តែ បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការអាចសម្រេចសេចក្ដីជំនួសការពិភាក្សា តាមការទាមទាររបស់ឪពុក ឬ ម្ដាយ បាន ។

៣-ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូនចំពោះអ្នកមានអំណាចមេបាបាន ។

**មាត្រា ១០៤២.–** ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន

លើកលែងតែករណីដែលមានភាពចាំបាច់បន្ទាន់ អ្នកដែលមានអំណាចមេបា ត្រូវពិភាក្សាជាមួយឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា អំពីចំណុចដែលទាក់ទងទៅនឹងកូន ដូចមានកំណត់ខាងក្រោមនេះ :

ក-ការអប់រំរបស់កូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំដែលជាករណីយកិច្ចកំណត់ដោយច្បាប់ ។

ខ-ការផ្លាស់ប្ដូរទីសំណាក់របស់កូន ពីខេត្ត-ក្រុងមួយ ទៅខេត្ត-ក្រុងមួយទៀត ។

គ-វិជ្ជាជីវៈ ឬ អាជីវកម្មរបស់កូន ។

ឃ-សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន ។

ង-ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន ។

ច-ចំណុចសំខាន់ៗផ្សេងទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងថែរក្សាកូន និងទ្រព្យសម្បត្តិរបស់កូន ។

## ផ្នែកទី ៣

## សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា

**មាត្រា ១០៤៣.–** ការអប់រំកូន

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចអប់រំកូន ។

**មាត្រា ១០៤៤.–** ទីសំណាក់របស់កូន

ទីសំណាក់របស់កូន ត្រូវកំណត់នៅទីកន្លែងដែលអ្នកមានអំណាចមេបា បានកំណត់ ។

**មាត្រា ១០៤៥.–** ការដាក់ទណ្ឌកម្មកូន

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូន ដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន ។

**មាត្រា ១០៤៦.–** ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ និង អាជីវកម្ម

១-កូន មិនអាចប្រកបវិជ្ជាជីវៈបានឡើយ បើមិនបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) នៃក្រមនេះ អ្នកមានអំណាចមេបា អាចលុបចោល ឬ កម្រិតការអនុញ្ញាត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះបាន ។

**មាត្រា ១០៤៧.–** ការទាមទារឱ្យប្រគល់កូន

១-អ្នកមានអំណាចមេបា អាចទាមទារឱ្យតតិយជន ដែលមិនព្រមប្រគល់កូន ដោយផ្ទុយនឹងច្បាប់ ប្រគល់កូនបាន ។

២-អ្នកមានអំណាចមេបា អាចទាមទារឱ្យឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា ប្រគល់កូនបាន ។

## ផ្នែកទី ៤
## ការល្បួរ និង ការដកហូតអំណាចមេបា

**មាត្រា ១០៤៨.–** ការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា

បើឪពុក ឬ ម្ដាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បើបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសល្បួរ ឬ ការដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការ បាន ។

**មាត្រា ១០៤៩.–** ការលុបចោលនូវការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា ១០៤៨ (ការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា) ខាងលើនេះ បានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសការ

ល្បូរ ឬ ការដកហូតសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការល្បូរ ឬ ការដកហូតអំណាចមេបា ឬ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់ជននោះបាន ។

**មាត្រា ១០៥០.–** ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា

១-បើមានមូលហេតុដែលពុំអាចជៀសវាងបាន ឪពុក ឬ ម្ដាយ ដែលអនុវត្តអំណាចមេបា អាចលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវបានបញ្ចប់ហើយ ឪពុក ឬ ម្ដាយ ដែលបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា អាចទទួលបដិទាននូវអំណាចមេបានោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៥១.–** ការផ្លាស់ប្ដូរអ្នកមានអំណាចមេបា

១-ក្នុងករណីដែលឪពុកម្ដាយតែម្ខាង ជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ទៅក្នុងស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ដោយសារអ្នកនោះត្រូវបានប្រកាសការល្បូរ ឬ ការដកហូតអំណាចមេបា ឬ បានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា មកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន ។

២-ប្រសិនបើមានការចាំបាច់ ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

៣-នៅពេលលែងលះគ្នា ប្រសិនបើឪពុក ឬ ម្ដាយ ដែលធ្វើជាអ្នកមានអំណាចមេបារបស់កូន តាមការពិភាក្សា បានទទួលមរណភាព ប្រសិនបើកូនពុំមានអ្នកមានអំណាចមេបាទេ ឪពុក ឬ ម្ដាយ ដែលពុំបានធ្វើជាអ្នកមានអំណាចមេបា ត្រូវក្លាយជាអ្នកមានអំណាចមេបា ។

**មាត្រា ១០៥២.–** ការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន

១-បើមានស្ថានភាពដែលពុំមានអ្នកមានអំណាចមេបា ចំពោះកូន តាមបញ្ញត្តិនៃមាត្រា ១០៤៨ (ការប្រកាសការល្វះ ឬ ការដកហូតអំណាចមេបា) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៥០ (ការលាឈប់ និង បដិទានរបស់អ្នកមានអំណាចមេបា) ហើយបើពុំបានផ្លាស់ប្តូរអ្នកមានអំណាចមេបា តាមបញ្ញត្តិនៃមាត្រា ១០៥១ (ការផ្លាស់ប្តូរអ្នកមានអំណាចមេបា) ខាងលើនេះទេ អាណាព្យាបាលសម្រាប់អនីតិជនចំពោះកូននោះ ត្រូវចាប់ផ្តើម តាមបញ្ញត្តិនៃមាត្រា ១០៦៧ (មូលហេតុនៃការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន) ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ១០៦៨ (អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូលដ្ឋាននៃការជ្រើសតាំង) ។

## ផ្នែកទី ៥
## សិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន

**មាត្រា ១០៥៣.–** ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ក្នុងការតំណាងឱ្យកូននោះ ចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ បើសកម្មភាពរបស់អ្នកមានអំណាចមេបា បង្កើតកាតព្វកិច្ច ដែលមានកម្មវត្ថុជាសកម្មភាពរបស់កូននោះ អ្នកមានអំណាចមេបា ត្រូវទទួលការយល់ព្រមពីកូននោះ ។

**មាត្រា ១០៥៤.–** សកម្មភាពដែលអ្នកមានអំណាចមេបាតែម្ខាងបានធ្វើ ក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង

១-បើឪពុក ឬ ម្តាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួម ធ្វើសកម្ម-

ភាពណាមួយជំនួសកូន ក្នុងនាមជាអ្នកមានអំណាចមេបាទាំងសងខាង ទោះជាសកម្មភាពនោះ ផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្តាយម្ខាងទៀតក៏ដោយ អានុភាពនៃសកម្មភាពនោះ ពុំត្រូវបានរារាំងឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀត នៃសកម្មភាពនោះ មានបំណងទុច្ចរិត ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលឪពុក ឬ ម្តាយណាម្ខាង ក្នុងចំណោមអ្នកមានអំណាចមេបារួម បានយល់ព្រមឱ្យកូនធ្វើសកម្មភាពណាមួយ ទោះបីជាសកម្មភាពនោះ ផ្ទុយនឹងឆន្ទៈរបស់ឪពុក ឬ ម្តាយម្ខាងទៀតក៏ដោយ ។

**មាត្រា ១០៥៥.–** ករណីយកិច្ចប្រុងប្រយ័ត្ន នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

អ្នកមានអំណាចមេបា ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

**មាត្រា ១០៥៦.–** ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ

បើកូនបានក្លាយជានីតិជនហើយ អ្នកមានអំណាចមេបា ត្រូវគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ សោហ៊ុយចិញ្ចឹមបីបាច់កូននោះ និង សោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ត្រូវចាត់ទុកថាបានទូទាត់ជាមួយនឹងផលចំណូលពីទ្រព្យសម្បត្តិរបស់កូននោះ ។

**មាត្រា ១០៥៧.–** បញ្ញត្តិពិសេស

បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ (ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះទ្រព្យសម្បត្តិដែលត្រូវបានផ្តល់ដោយមិនគិតថ្លៃទៅឱ្យកូន ដោយតតិយជនដែលបានបង្ហាញឆន្ទៈផ្ទុយនឹងវាក្យខណ្ឌទី ២ នៃមាត្រា ១០៥៦ នោះ ។

**មាត្រា ១០៥៨.–** ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្តល់ទៅឱ្យកូន

១-ប្រសិនបើតតិយជនដែលបានផ្តល់ទ្រព្យសម្បត្តិឱ្យទៅកូនដោយមិនគិតថ្លៃ បាន

បង្ហាញឆន្ទៈថា មិនឱ្យឪពុកម្ដាយណាម្ខាង ឬ ទាំងសងខាង ដែលអនុវត្តអំណាចមេបា គ្រប់គ្រងទ្រព្យសម្បត្តិនោះទេ ទ្រព្យសម្បត្តិនោះ ពុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្ដាយណាម្ខាង ឬ ទាំងសងខាងឡើយ ។

២-ក្នុងករណីដែលអ្នកមានអំណាចមេបា ពុំបានអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើតតិយជនពុំបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ តាមការទាមទាររបស់កូន ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន ឬ តំណាងអយ្យការបាន ។

៣-ទោះបីជាតតិយជនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាដែរ នៅក្នុងករណីដែលសិទ្ធិអំណាចរបស់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះ បានរលត់ ឬ មានការចាំបាច់ត្រូវផ្លាស់ប្ដូរអ្នកនោះ តែតតិយជននោះ មិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិផ្សេងទៀត ។

៤-បញ្ញត្តិចាប់ពីមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) រហូតដល់មាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ ។

**មាត្រា ១០៥៩.–** ការអនុវត្តដូចគ្នានៃបញ្ញត្តិស្ដីពីអាណត្តិ

បញ្ញត្តិនៃមាត្រា ៦៩០ (ករណីយកិច្ចសង្គ្រោះបន្ទាន់ របស់អាណត្តិគាហក នៅក្រោយពេលបញ្ចប់អាណត្តិ) និង មាត្រា ៦៩១ (លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណត្តិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកមានអំណាចមេបា ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និង ករណីដែលបានកំណត់នៅក្នុងមាត្រា ១០៥៨ (ការគ្រប់គ្រងទ្រព្យសម្បត្តិដែលតតិយជនបានផ្ដល់ទៅឱ្យកូន) ខាងលើនេះ ។

**មាត្រា ១០៦០.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសម្បត្តិ រវាងឪពុកម្ដាយ និង កូន

១-សិទ្ធិលើបំណុលដែលកើតឡើងរវាងអ្នកមានអំណាចមេបា និង កូន ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវរលត់ដោយអាជ្ញាយុកាល បើពុំបានអនុវត្តសិទ្ធិនោះ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិអំណាចនៃការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ ។

២-ក្នុងករណីដែលសិទ្ធិអំណាចក្នុងការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ បានរលត់នៅក្នុងពេលដែលកូនពុំទាន់ក្លាយជានីតិជន បើកូនពុំមានអ្នកតំណាងដែលច្បាប់បានកំណត់ អំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវគណនាអំឡុងពេល ដោយគិតចាប់ពីពេលដែលកូននោះក្លាយជានីតិជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ ដែលស្នងបន្តនោះ បានឡើងកាន់តំណែង ។

## ផ្នែកទី ៦
## ការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

**មាត្រា ១០៦១.–** ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើអ្នកមានអំណាចមេបា បានធ្វើឱ្យអន្តរាយដល់ទ្រព្យសម្បត្តិរបស់កូន ដោយសារការគ្រប់គ្រងមិនត្រឹមត្រូវ តុលាការអាចប្រកាសព្យួរ ឬ ដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រង តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

**មាត្រា ១០៦២.–** ការលុបចោលការប្រកាសការព្យួរ និង ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ១០៦១ (ការប្រកាសការព្យួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះ បានបញ្ចប់ហើយ តុលាការ

អាចលុបចោលការប្រកាសការល្បួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ តាមការទាមទាររបស់សាមីជនដែលបានទទួលការប្រកាសការល្បួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ឬ ញាតិក្នុង៤ (បួន) ថ្នាក់របស់ជននោះ បាន ។

**មាត្រា ១០៦៣.–** ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ

១-បើមានមូលហេតុពុំអាចជៀសវាងបាន អ្នកមានអំណាចមេបា អាចលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បានបញ្ចប់ហើយអ្នកមានអំណាចមេបាដែលបានលាឈប់ពីសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ អាចទទួលបដិទាននូវសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិនោះវិញបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១០៦៤.–** ករណីដែលពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ

បើពុំមានអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិ តាមបញ្ញត្តិនៃមាត្រា ១០៦១ (ការប្រកាសការល្បួរ ឬ ការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ឬ កថាខណ្ឌទី ១ នៃមាត្រា ១០៦៣ (ការលាឈប់ និង បដិទាននៃការគ្រប់គ្រងទ្រព្យសម្បត្តិ) ខាងលើនេះទេ តុលាការត្រូវសម្រេចសេចក្តីជ្រើសតាំងអ្នកតំណាងពិសេស ឱ្យកូន ។

**មាត្រា ១០៦៥.–** ករណីដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា

១-ចំពោះសកម្មភាពដែលផលប្រយោជន៍របស់អ្នកមានអំណាចមេបា និង កូន មានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេស សម្រាប់កូន ។

២-ក្នុងករណីដែលអ្នកមានអំណាចមេបា អនុវត្តអំណាចមេបាចំពោះកូនច្រើននាក់ ចំពោះសកម្មភាពដែលផលប្រយោជន៍របស់កូនម្នាក់នោះ និង កូនផ្សេងទៀត មានភាពផ្ទុយគ្នា អ្នកមានអំណាចមេបា ត្រូវទាមទារឱ្យតុលាការជ្រើសតាំងអ្នកតំណាងពិសេស

សម្រាប់កូនណាម្នាង ។

## ផ្នែកទី ៧
## ការយកមកអនុវត្តដូចគ្នានៃជំពូកនេះ

**មាត្រា ១០៦៦.–** អ្នកជំនួសអំណាចមេបា

ចំពោះកូនរបស់អនីតិជនដែលមិនទាន់បានរៀបអាពាហ៍ពិពាហ៍ អ្នកមានអំណាចមេបារបស់អនីតិជននោះ ត្រូវអនុវត្តអំណាចមេបាជំនួស ។ ក្នុងករណីនេះ បញ្ញត្តិនៃជំពូកទី ៥ (អំណាចមេបា) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះអ្នកដែលអនុវត្តអំណាចមេបាជំនួស ។

# ជំពូកទី ៦
# អាណាព្យាបាល

## ផ្នែកទី ១
## អាណាព្យាបាលសម្រាប់អនីតិជន

### កថាភាគទី ១
### ការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៧.–** មូលហេតុនៃការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើគ្មានអ្នកអនុវត្តអំណាចមេបាចំពោះអនីតិជនទេ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវចាប់ផ្តើម ។

### កថាភាគទី ២
### អ្នកអាណាព្យាបាលសម្រាប់អនីតិជន

**មាត្រា ១០៦៨.–** អ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានកំណត់ អ្នក

អាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំង និង មូល-
ដ្ឋាននៃការជ្រើសតាំង

១-អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់ចំពោះអនីតិជន អាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមមតកសាសន៍បាន ។

២-ប្រសិនបើគ្មានអ្នកត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះទេ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់អនីតិជន មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

៣-ដើម្បីជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តុលាការត្រូវគិតពិចារណាអំពីស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត និង ស្ថានភាពជីវភាព និង ទ្រព្យសម្បត្តិរបស់អនីតិជន វិជ្ជាជីវៈ និង ប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អត្ថិភាព ឬ នត្ថិភាព នៃទំនាក់ទំនងទៅនឹងផលប្រយោជន៍ រវាងអ្នកធ្វើជាអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អនីតិជន យោបល់របស់អនីតិជន និង ស្ថានភាពផ្សេងទៀតទាំងស្រុង ។

**មាត្រា ១០៦៩.–** ករណីយកិច្ចជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ប្រសិនបើខ្វះអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ១០៥២ (ការចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន) នៃក្រមនេះ តុលាការត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មីទៀត ឱ្យបានឆាប់រហ័ស ។

**មាត្រា ១០៧០.–** ចំនួននៃអ្នកអាណាព្យាបាលសម្រាប់អនីតិជន

១-អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានតែម្នាក់ ។ ប៉ុន្តែ ចំពោះអនីតិជននៅក្រោមអាណាព្យាបាលដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ ដែលខ្វះសមត្ថភាពក្នុងការ

ឧបសម្ព័ន្ធទី២

ឯកសារទាក់ទងនឹងដីកាសម្រេចសុំកូនពេញលេញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តស្ទឹងត្រែង**

លេខ ................រ.ព/២០២០

## ដីកាសម្រេច

**យើង [redacted] ចៅក្រម សាលាដំបូងខេត្តស្ទឹងត្រែង**

បានឃើញ មាត្រា៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

បានឃើញ មាត្រា ១០០៧ មាត្រា ១០១៥ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី។

បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីនីតិវិធីមិនមែនបណ្តឹងលេខ ៥ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្ទឹងត្រែង។

**ជនដាក់ពាក្យសុំ**ឈ្មោះ [redacted] ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិខ្មែរ មុខរបរ អាជីវករ និងប្រពន្ធឈ្មោះ [redacted] អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ មុខរបរ អាជីវករ ទីលំនៅបច្ចុប្បន្ន នៅភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**ភាគីម្ខាងទៀត**ឈ្មោះ [redacted] ភេទស្រី អាយុ ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីលំនៅបច្ចុប្បន្ន នៅភូមិខាំផាន់ សង្កាត់សាមគ្គី ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

**ការទាមទាររបស់ជនដាក់ពាក្យសុំ ឱ្យតុលាការចេញដីកាសម្រេច៖**

១-បង្កើតស្មុំកូនពេញលេញរវាងឪពុកចិញ្ចឹមឈ្មោះ [redacted] និងម្តាយចិញ្ចឹមឈ្មោះ [redacted] ជាមួយកូនចិញ្ចឹមឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៩

២-ឱ្យជនដាក់ពាក្យសុំជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

### សំអាងហេតុ

១-កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានរៀបអាពាហ៍ពិពាហ៍នៅភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ហើយក្នុងពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] មិនមានកូន។ បន្ទាប់មកនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩ ភាគីម្ខាងទៀតឈ្មោះ [redacted] បានប្រគល់កូនស្រីឈ្មោះ [redacted] កើតនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៩ ឱ្យទៅជនដាក់ពាក្យសុំឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ដើម្បីយកទៅចិញ្ចឹមធ្វើជាកូន តាមកិច្ចសន្យាប្រគល់កូន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩។

២-ចាប់ពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩ រហូតមកដល់ពេលនេះ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] ចិញ្ចឹមបីបាច់កូនស្រីឈ្មោះ [redacted] បានរយៈពេល ៦ (ប្រាំមួយ) ខែ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ ឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted] បានដាក់ពាក្យសុំ នៅសាលាដំបូងខេត្តស្ទឹងត្រែង ឱ្យតុលាការចេញដីកាសម្រេច បង្កើតស្មុំកូនពេញលេញរវាងពួកគាត់ និងកូនចិញ្ចឹមឈ្មោះ [redacted]

[redacted] កើតនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៩ នោះ មានមូលដ្ឋានគ្រប់គ្រាន់។ ដូចនេះតុលាការគប្បីចេញដីកាសម្រេចតាមពាក្យសុំ។

**សេចក្តីសម្រេចបញ្ចប់**

១-ទទួលស្គាល់ពាក្យសុំរបស់ឈ្មោះ [redacted] និងឈ្មោះ [redacted] ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០ ធ្វើឡើងតាមទម្រង់ និងគតិច្បាប់។

២-បង្កើតស្ម័កូនពេញលេញរវាងជនដាក់ពាក្យសុំឈ្មោះ [redacted] និងឈ្មោះ [redacted] ជាឪពុកម្តាយចិញ្ចឹម និងកូនចិញ្ចឹមឈ្មោះ [redacted] ភេទស្រី កើតនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៩។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ជនដាក់ពាក្យសុំ។

៤-ដីកាសម្រេចនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា។

ថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅស្ទឹងត្រែង,ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅស្ទឹងត្រែង,ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រម**

**ឧបសម្ព័ន្ធទី៣**

**ឯកសារទាក់ទងនឹងដីកាសម្រេចលែងលះដោយការព្រមព្រៀង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តស្ទឹងត្រែង**

## ដីកាសម្រេច

លេខ [redacted]/២០២២

**យើង [redacted] ចៅក្រម សាលាដំបូងខេត្តស្ទឹងត្រែង**

បានឃើញ មាត្រា៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង។

បានឃើញ មាត្រា ៩៧៩ មាត្រា ១០៣៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីនីតិវិធីមិនមែនបណ្ដឹងលេខ ៨២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តស្ទឹងត្រែង។

**ជនដាក់ញ្ញសុំ**ឈ្មោះ [redacted] ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីលំនៅបច្ចុប្បន្ន នៅភូមិហាងសាវ៉ាត ឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង។

មេធាវីតំណាងដោយអាណត្តិ គ្មាន។

**ភាគីម្ខាងទៀត**ឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្ន នៅភូមិច្រប់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។

មេធាវីតំណាងដោយអាណត្តិ គ្មាន។

**ខ្លឹមសារនៃដីកាសម្រេចដែលជនដាក់ពាក្យសុំ សុំឱ្យតុលាការសម្រេច៖**

១-លែងលះគាត់ពីភាគីម្ខាងទៀតឈ្មោះ [redacted] និង

២-ឱ្យគាត់ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤។

៣-ឱ្យភាគីម្ខាងទៀតឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនចំនួន ២ (ពីរ) នាក់ ម្នាក់ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ និងម្នាក់ទៀតឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។

៤-ឱ្យគាត់ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

## សំអាងហេតុ

១-កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៤ ឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើពិធីរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី នៅភូមិហាងសាវ៉ាត ឃុំសាមឃួយ ស្រុកសេសាន ខេត្តស្ទឹងត្រែង ហើយនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ បានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ នៅសាលាឃុំសាមឃួយ។ ក្នុងពេលរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធ ឈ្មោះ [redacted] និងឈ្មោះ [redacted] មានកូនចំនួន ៣ (បី) នាក់ កូនទី១ ឈ្មោះ [redacted] ភេទស្រី កើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ កូនទី២ ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ និងកូនទី៣ ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃ ទី១២ ខែមិថុនា ឆ្នាំ២០២០ មានទ្រព្យសម្បត្តិរួម ដីលំនៅឋានចំនួន ១ (មួយ) កន្លែង ទទឹងប្រវែង ៤០ ម៉ែត្រ និងបណ្ដោយប្រវែង ៤០ (សែសិប) ម៉ែត្រ ស្ថិតនៅភូមិច្រប់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង គោយន្តកន្ត្រៃយ៍ចំនួន ១ (មួយ) គ្រឿង ម៉ូតូម៉ាកវ៉េវអាល់ហ្វា គ្មានស្លាកលេខចំនួន ១ (មួយ) គ្រឿង និងមានបំណុលរួមនៅជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ចំនួន ២០,០០០,០០០ (ម្ភៃ)លានរៀល ប្រាកដមែន។

៣-ក្នុងឆ្នាំ២០២១ ឈ្មោះ [redacted] និងឈ្មោះ [redacted] រស់នៅមិនចុះសម្រុងនឹងគ្នា លុះដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២១ បានធ្វើកិច្ចព្រមព្រៀងលែងលះដោយឱ្យឈ្មោះ [redacted] ជាអ្នកមានអំណាច

មេបាលើកូនស្រីឈ្មោះ [redacted] កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ចំណែក កូនចំនួន ២ (ពីរ) នាក់ ម្នាក់ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៧ និងម្នាក់ទៀត ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ឲ្យឈ្មោះ [redacted] ជាអ្នកមានអំណាចមេបា។ ចំពោះទ្រព្យសម្បត្តិរួម ដីលំនៅឋានចំនួន ១ (មួយ) កន្លែង ទទឹងប្រវែង ៤០ ម៉ែត្រ និងបណ្ដោយប្រវែង ៤០ ម៉ែត្រ ស្ថិតនៅភូមិច្រប់ ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង គោយន្តម៉ាកកន្ត្រៃយ៍ ចំនួន ១ (មួយ) គ្រឿង ម៉ូតូម៉ាកវ៉េអាល់ហ្វា គ្មានស្លាកលេខចំនួន ១ (មួយ) គ្រឿង ឲ្យភាគីម្ខាងទៀត ឈ្មោះ [redacted] ជាអ្នកមានសិទ្ធចាត់ចែង និងជាអ្នកទទួលបន្ទុកសងបំណុលរួម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) សាខាខេត្តស្ទឹងត្រែង ចំនួន២០,០០០,០០០ (ម្ភៃ) លានរៀល ប្រាកដមែន ។

៤-នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ឈ្មោះ [redacted] បានមកដាក់ពាក្យសុំនៅសាលាដំបូងខេត្តស្ទឹងត្រែង សុំឱ្យតុលាការចេញដីកាសម្រេចលែងលះគាត់ពីឈ្មោះ [redacted] ឱ្យគាត់ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ និងឱ្យភាគីម្ខាងទៀតឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនចំនួន ២ (ពីរ) នាក់ម្នាក់ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៧ និងម្នាក់ទៀតឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១២ ខែ មិថុនា ឆ្នាំ ២០២០ ដោយមានការព្រមព្រៀងពីឈ្មោះ [redacted]។ ដូចនេះ បង្ហាញឱ្យឃើញថា ឈ្មោះ [redacted] និងឈ្មោះ [redacted] ពិតជាមានបំណងក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ប្រាកដមែន។

**សេចក្ដីសម្រេចបញ្ចប់**

១-ទទួលស្គាល់ពាក្យសុំ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ជនដាក់ពាក្យសុំឈ្មោះ [redacted] ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២- លែងលះឈ្មោះ [redacted] ពីភាគីម្ខាងទៀតឈ្មោះ [redacted]។

៣-ឱ្យឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤។ ប៉ុន្តែឈ្មោះ [redacted] ត្រូវអនុញ្ញាតឱ្យឈ្មោះ [redacted] ជាឪពុកមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន។

៤-ឱ្យឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនចំនួន២ (ពីរ) នាក់ ម្នាក់ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី ២៨ ខែមករា ឆ្នាំ២០១៧ និងម្នាក់ទៀតឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០២០។ ប៉ុន្តែឈ្មោះ [redacted] ត្រូវអនុញ្ញាតឱ្យឈ្មោះ [redacted] ជា ម្ដាយមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ជនដាក់ពាក្យសុំ។

៦-ដីកាសម្រេចនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចូលជាស្ថាពរ។

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

ធ្វើនៅស្ទឹងត្រែង,ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥

ធ្វើនៅស្ទឹងត្រែង,ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រម**

## ឯកសារទាក់ទងនឹងសាលក្រមលែងលះតាមពាក្យបណ្តឹង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តស្ទឹងត្រែង**

សំណុំរឿងរដ្ឋប្បវេណីលេខ ៤៦
ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨
សាលក្រមលេខ ៤៧ (ក)
ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តស្ទឹងត្រែង**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១។

**ចៅក្រមជំនុំជម្រះ**

ឯកឧត្តមបណ្ឌិត [redacted] ចៅក្រម សាលាដំបូងខេត្តស្ទឹងត្រែង

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តស្ទឹងត្រែង

ដើមចោទឈ្មោះ [redacted] ភេទស្រី អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ មុខរបរ មេផ្ទះ ទីលំនៅបច្ចុប្បន្ន នៅភូមិ-ឃុំ-ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

មេធាវីតំណាងដោយអាណត្តិ លោក [redacted]។

ចុងចម្លើយឈ្មោះ [redacted] ភេទប្រុស អាយុ ៤២ឆ្នាំ ជនជាតិខ្មែរ មុខរបរ យោធា ទីលំនៅបច្ចុប្បន្ន នៅភូមិ-ឃុំ-ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

មេធាវីតំណាងដោយអាណត្តិ គ្មាន។

**ខ្លឹមសារនៃសាលក្រមដែលដើមចោទសុំតុលាការសម្រេចៈ**

១-លែងលះគាត់ពីចុងចម្លើយឈ្មោះ [redacted]
២-ឱ្យគាត់ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរួមទាំងអស់ទុកសម្រាប់កូនចំនួន ៤(បួន) នាក់
៣-ឱ្យគាត់ជាអ្នកមានអំណាចមេបាលើកូនចំនួន ៤ (បួន) នាក់
៤-ឱ្យចុងចម្លើយឈ្មោះ [redacted] ផ្តល់អាហារកិច្ចចិញ្ចឹមកូនទាំង ៤ (បួន) នាក់ និង
៥-ឱ្យគាត់ និងចុងចម្លើយឈ្មោះ [redacted] ទទួលបន្ទុកសងបំណុលរួមក្នុងចំណែកស្មើៗគ្នា។

**អង្គហេតុ និងចំណុចវិវាទ**

កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៤ ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានរៀបអាពាហ៍ពិពាហ៍ នៅភូមិ-ឃុំ-ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ហើយក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ មានកូនចំនួន ៤ (បួន) នាក់ ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ ១២ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ ៩ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៦ឆ្នាំ មានទ្រព្យសម្បត្តិរួម និងបំណុលរួម។ ចាប់តាំងពីឆ្នាំ២០១៦ ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] រស់នៅមិនចុះសម្រុងនឹងគ្នាបានបែកលំនៅដ្ឋានពីគ្នា ដែលជាហេតុធ្វើឱ្យដើមចោទឈ្មោះ [redacted] អស់មនោសញ្ចេតនាក្នុងការរួមរស់ជាគ្នាជាប្តីប្រពន្ធបន្តទៀត។ បន្ទាប់មក

នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ ដើមចោទឈ្មោះ [redacted] បានមកដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តស្ទឹងត្រែង សុំតុលាការចេញសាលក្រមសម្រេច លែងលះគាត់ពីចុងចម្លើយឈ្មោះ [redacted] ឱ្យគាត់ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរួមទុកសម្រាប់កូនទាំង ៤ (បួន) នាក់ ឱ្យគាត់ជាអ្នកមានអំណាចមេបាលើកូនទាំង ៤ (បួន) នាក់ ឱ្យចុងចម្លើយឈ្មោះ [redacted] ផ្តល់អាហារកិច្ចចិញ្ចឹមកូនទាំង ៤ (បួន) នាក់ និងឱ្យគាត់ និងចុងចម្លើយឈ្មោះ [redacted] ទទួលបន្ទុកសងបំណុលរួមក្នុងចំណែកស្មើៗគ្នា។ ប៉ុន្តែនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម។

**សេចក្តីថ្លែងការណ៍របស់ដើមចោទ**

លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ធ្វើសេចក្តីថ្លែងការណ៍ថា កាលពីក្នុងឆ្នាំ២០០៤ កូនក្តីរបស់គាត់ឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានរៀបអាពាហ៍ពិពាហ៍ នៅភូមិ-ឃុំ-ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ហើយក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធមានកូនចំនួន ៤ (បួន) នាក់ មានទ្រព្យសម្បត្តិរួម និងបំណុលរួម។ ចាប់តាំងពីឆ្នាំ២០១៦ កូនក្តីរបស់គាត់ឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] រស់នៅមិនចុះសម្រុងនឹងគ្នាបានបែកលំនៅដ្ឋានពីគ្នាដែលធ្វើឱ្យអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្តីប្រពន្ធបន្តទៀត ហើយនៅថ្ងៃទី៣០ ខែមិថុនាឆ្នាំ២០១៨ កូនក្តីរបស់គាត់ឈ្មោះ [redacted] បានមកដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តស្ទឹងត្រែងសុំតុលាការចេញសាលក្រមសម្រេច៖

១-លែងលះកូនក្តីរបស់គាត់ឈ្មោះ [redacted] ពីចុងចម្លើយឈ្មោះ [redacted]

២-ឱ្យកូនក្តីរបស់គាត់ឈ្មោះ [redacted] ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរួមទុកឱ្យកូនទាំង ៤ (បួន) នាក់

៣-ឱ្យកូនក្តីរបស់គាត់ឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនចំនួន ៤ (បួន) នាក់

៤-ឱ្យចុងចម្លើយឈ្មោះ [redacted] ផ្តល់អាហារកិច្ចចិញ្ចឹមកូនទាំង ៤ (បួន) នាក់ និង

៥-ឱ្យគាត់ និងចុងចម្លើយឈ្មោះ [redacted] ទទួលបន្ទុកសងបំណុលរួមក្នុងចំណែកស្មើៗគ្នា។ ប៉ុន្តែកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ កូនក្តីរបស់គាត់ឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម ហើយនៅក្នុងកិច្ចព្រមព្រៀងនេះ បានធ្វើការបែងចែកទ្រព្យសម្បត្តិរួម និងបំណុលរួម និងបានកំណត់អ្នកមានអំណាចមេបាលើកូនចំនួន ៤ (បួន) នាក់។ ដូចនេះសុំតុលាការចេញសាលក្រមសម្រេច៖

១-លែងលះកូនក្តីរបស់គាត់ឈ្មោះ [redacted] ពីចុងចម្លើយឈ្មោះ [redacted]

២-ឱ្យកូនក្តីរបស់គាត់ឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ [redacted] អាយុ ៩ឆ្នាំ និងកូនស្រីម្នាក់ឈ្មោះ [redacted] អាយុ ៦ឆ្នាំ

៣-ឱ្យចុងចម្លើយឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនប្រុសចំនួន ២ (ពីរ) នាក់ម្នាក់ឈ្មោះ [redacted] អាយុ ១៦ឆ្នាំ និងម្នាក់ទៀតឈ្មោះ [redacted] អាយុ ១២ឆ្នាំ។

**សេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយ**

ចុងចម្លើយឈ្មោះ [redacted] ធ្វើសេចក្តីថ្លែងការណ៍តបថា គាត់យល់ព្រមតាមសេចក្តីថ្លែងការណ៍របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ទាំងអស់ ដោយសារកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ គាត់ និងដើមចោទឈ្មោះ [redacted] បានធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម ហើយនៅក្នុងកិច្ចព្រមព្រៀងនេះ បានធ្វើការបែងចែកទ្រព្យសម្បត្តិរួម និងបំណុល

រួម និងបានកំណត់អ្នកមានអំណាចមេបាលើកូនចំនួន ៤ (បួន) នាក់ រួចហើយ ដោយមានលោក [redacted] ជាមេធាវីធ្វើជាសាក្សីដឹងឮ។

## សំអាងហេតុ

១-កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៤ ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានរៀបអាពាហ៍ពិពាហ៍ នៅភូមិ-ឃុំ-ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ហើយក្នុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ មានកូនចំនួន ៤ (បួន) នាក់ ឈ្មោះ [redacted] ភេទប្រុស អាយុ ១៦ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ ១២ឆ្នាំ ឈ្មោះ [redacted] ភេទប្រុស អាយុ ៩ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៦ឆ្នាំ មានទ្រព្យសម្បត្តិរួម និងបំណុលរួម។ ចាប់តាំងពីឆ្នាំ២០១៦ ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] រស់នៅមិនចុះសម្រុងនឹងគ្នាបានបែកលំនៅដ្ឋានពីគ្នា ប្រាកដមែន។

២-នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ ដើមចោទឈ្មោះ [redacted] បានមកដាក់ពាក្យបណ្តឹងនៅសាលាដំបូងខេត្តស្ទឹងត្រែង សុំតុលាការចេញសាលក្រមសម្រេច លែងលះគាត់ពីចុងចម្លើយឈ្មោះ [redacted] ឱ្យគាត់ជាអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរួមទុកសម្រាប់កូនទាំង ៤ (បួន) នាក់ ឱ្យគាត់ជាអ្នកមានអំណាចមេបាលើកូន ទាំង ៤ (បួន) នាក់ ឱ្យចុងចម្លើយឈ្មោះ [redacted] ផ្តល់ អាហារកិច្ចចិញ្ចឹមកូនទាំង ៤ (បួន) នាក់ និងឱ្យគាត់ និងចុងចម្លើយឈ្មោះ [redacted] ទទួលបន្ទុកសងបំណុលរួមក្នុងចំណែកស្មើៗគ្នា ប្រាកដមែន។

៣-នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម ហើយនៅក្នុងកិច្ចព្រមព្រៀងនេះ បានធ្វើការបែងចែកទ្រព្យសម្បត្តិរួម និងបំណុលរួម និងបានកំណត់អ្នកមានអំណាចមេបាលើកូនចំនួន ៤ (បួន) នាក់ ដោយឱ្យដើមចោទឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ [redacted] អាយុ ៩ឆ្នាំ និងកូនស្រីម្នាក់ឈ្មោះ [redacted] អាយុ ៦ឆ្នាំ និងឱ្យចុងចម្លើយឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនប្រុសចំនួន ២ (ពីរ) នាក់ ម្នាក់ឈ្មោះ [redacted] អាយុ ១៦ឆ្នាំ និងម្នាក់ទៀតឈ្មោះ [redacted] អាយុ ១២ឆ្នាំ ប្រាកដមែន។

៤-នៅពេលទាញហេតុផលដោយផ្ទាល់មាត់ លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានសុំឱ្យតុលាការចេញសាលក្រមសម្រេចពីការលែងលះ និងកំណត់អ្នកមានអំណាចមេបាលើកូនទាំង ៤ (បួន) នាក់ តាមកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ នោះ មានមូលដ្ឋានត្រឹមត្រូវតាមច្បាប់។ ដូចនេះ តុលាការគប្បីលើកយកមកពិចារណា។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលស្គាល់ពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ របស់ដើមចោទឈ្មោះ [redacted] ធ្វើឡើងត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-លែងលះដើមចោទឈ្មោះ [redacted] ពីចុងចម្លើយឈ្មោះ [redacted]។ ប៉ុន្តែដើមចោទឈ្មោះ [redacted] ត្រូវស្ថិតនៅក្នុងភាពមេម៉ាយចំនួន ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រម។

៣-ឱ្យដើមចោទឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនប្រុសម្នាក់ឈ្មោះ [redacted] អាយុ ៩ឆ្នាំ និងកូនស្រីម្នាក់ឈ្មោះ [redacted] អាយុ ៦ឆ្នាំ។ ប៉ុន្តែដើមចោទឈ្មោះ [redacted] ត្រូវអនុញ្ញាតឱ្យចុងចម្លើយឈ្មោះ [redacted] ជាឪពុកមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន។

៤-ឱ្យចុងចម្លើយឈ្មោះ [redacted] ជាអ្នកមានអំណាចមេបាលើកូនប្រុសចំនួន ២ (ពីរ) នាក់ ម្នាក់ឈ្មោះ [redacted] អាយុ ១៦ឆ្នាំ និងម្នាក់ទៀងឈ្មោះ [redacted] អាយុ ១២ឆ្នាំ។ ប៉ុន្តែចុងចម្លើយឈ្មោះ [redacted] ត្រូវអនុញ្ញាតឱ្យដើមចោទឈ្មោះ [redacted] ជាម្ដាយមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

៦-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted]។ បើកសិទ្ធិប្ដឹងឧទ្ធរណ៍តាមច្បាប់កំណត់។

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅស្ទឹងត្រែង, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ធ្វើនៅស្ទឹងត្រែង, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

**បានឃើញ**
**ចៅក្រម**